**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# ប្រធានបទ
# នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា
# ដោយតុលាការនៅសាលាដំបូង

ស្រាវជ្រាវចាប់ពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៥

រៀបរៀងដោយៈ
សមណនិស្សិត **ផាន សុវណ្ណា**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ខុដ្ឋី**

ថ្នាក់បរិញ្ញាប័ត្រនីតិសាស្ត្រ
ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

ជាបឋមអាត្មាភាព ជាសមណនិស្សិត សូមសម្តែងនូវកតញ្ញូតាធម៌ និង ថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកអ្នកមានគុណទាំងអស់ដែលបានជួយជ្រោមជ្រែង អាត្មាភាពតាំងតែពីដើមរៀងមកមាន៖

លោកឪពុក អ្នកម្តាយ ជានិច្ចកាល តែងតែលះបង់ធនធានគ្រប់បែបយ៉ាងទាំងអស់ ដើម្បីការសិក្សារបស់កូន។

**ឯកឧត្តម** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង មន្ត្រីបុគ្គលិកគ្រប់ផ្នែក នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យអាត្មាភាព មានឱកាសបានបន្តការសិក្សានៅទីនេះ។

លោកសាស្ត្រាចារ្យ **ញឹក ឧុឆ្នី** ជានិច្ចកាលលោកបានណែនាំ ផ្តល់នូវកម្លាំងចិត្ត និង បញ្ញាសមត្ថភាពបច្ចេកទេសវិធីសាស្ត្រពេញនិយម ជួយបង្ហាញប្រកបដោយគតិបណ្ឌិតនូវរាល់ឯកសារនានា ដែលពាក់ព័ន្ធនឹងប្រធានបទរហូតដល់ការសិក្សាស្រាវជ្រាវនេះហើយទទួលបាននូវជោគជ័យជាស្ថាពរ។

លោកសាស្ត្រាចារ្យគ្រប់ខណ្ឌ និង វេលាការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្រៀន និងបណ្តុះបណ្តាលដល់រូបអាត្មាភាពកន្លងមក។

សូមប្រសិទ្ធិពរជ័យសិរីសួស្តីជ័យមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ ចូរកើតកើនមានដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា គ្រប់ក្រុមគ្រួសារហើយសម្រេចបានជោគជ័យទៅតាមបំណងដែលអស់លោកប៉ងប្រាថ្នាក្នុងវិជ្ជាជីវៈចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ និងទទួលបានជោគជ័យក្នុងជីវិត។

# អារម្ភកថា

នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូងនេះ មានមុខងារ និង តួនាទីយ៉ាងសកម្ម ក្នុងការដោះស្រាយវិវាទកិច្ចសន្យាជូនដល់ភាគីវិវាទកិច្ចសន្យា។ ពិតណាស់ ដំណោះស្រាយវិវាទកិច្ចសន្យាពិតជាមានសារៈប្រយោជន៍សំខាន់ខ្លាំងណាស់ សម្រាប់គូភាគីវិវាទកិច្ចសន្យា ក៏ដូចជាប្រជាពលរដ្ឋទូទៅ ពីព្រោះដំណោះស្រាយនេះអាចធ្វើឱ្យគូភាគីវិវាទបញ្ឈប់អំពើហិង្សា បញ្ចប់វិវាទ ហើយឈានទៅរកភាពសះជានឹងគ្នា រួមជីវភាពសេដ្ឋកិច្ច សង្គមកិច្ច និង ធ្វើឱ្យមានទំនាក់ទំនងល្អប្រសើរឡើងវិញ តាមរយៈដំណោះស្រាយល្អៗប្រកបដោយគតិបណ្ឌិតឈ្លាសវៃរបស់ចៅក្រម។ ផ្ទុយទៅវិញ ប្រសិនបើដំណោះស្រាយនោះមិនល្អវានឹងនាំឱ្យវិវាទនោះកើនឡើងទ្វេដងដល់គូភាគីវិវាទ និង ប្រជាពលរដ្ឋទូទៅ តាមរយៈការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង។ តុលាការសាលាដំបូងមានមុខងារ និងតួនាទីដោះស្រាយវិវាទកិច្ចសន្យា ស្វែងរកយុត្តិធម៌ឱ្យដល់ភាគីវិវាទកិច្ចសន្យា ។ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង មានគោលបំណងការពារសិទ្ធិស្របច្បាប់របស់ភាគីតាមរយៈការដោះស្រាយវិវាទកិច្ចសន្យាដោយផ្អែកទៅលើច្បាប់ធរមាន ដើម្បីការពារសិទ្ធិស្របច្បាប់របស់ភាគីនោះមាន។

ដោយយល់ឃើញថា «នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង» នេះជាកត្តាលីករជំរុញឱ្យគូភាគីវិវាទកិច្ចសន្យាមាននូវភាពសះជានឹងគ្នាបាន អាស្រ័យដោយការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង។សារណានេះនឹងធ្វើការបង្ហាញដល់និស្សិត ឬ អ្នកសិក្សាទាំងឡាយធ្វើការស្វែងយល់ថា តើប្រភពនៃវិវាទកិច្ចសន្យាកើតចេញពីអ្នកណា តើសមត្ថកិច្ចណាអាចដោះស្រាយវិវាទកិច្ចសន្យានេះបាន ? តើធ្វើដូចម្តេចដើម្បីឱ្យសមត្ថកិច្ចដែលមានការពាក់ព័ន្ធនោះអាចដោះស្រាយវិវាទកិច្ចសន្យានេះបាន ? «នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង»គឺផ្តល់ការសិក្សាស្វែងយល់អំពីសមត្ថកិច្ចរបស់សាលាជម្រះក្តី និង ការងារប្រតិបត្តិការណ៍របស់សមត្ថកិច្ច ដើម្បីជំរុញឱ្យយើងមានលទ្ធភាពក្នុងការមើលឃើញថា៖តើការដោះស្រាយវិវាទកិច្ចសន្យានេះមានឥទ្ធិពលយ៉ាងដូចម្តេចទៅ ក្នុងស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយវិវាទកិច្ចសន្យា និង សង្គមទាំងមូល។

ដើម្បីឱ្យមានភាពល្អប្រសើរលើវិស័យឯកជន ក្នុងទមនាក់ទំនងពាណិជ្ជកម្ម រួមជីវភាពសេដ្ឋកិច្ច និង សមតាមបំណងប្រាថ្នារបស់គូភាគី សមត្ថកិច្ចសាលាជម្រះក្តីត្រូវជំរុញឱ្យមានសុក្រឹត្យភាព និង យុត្តិធម៌ត្រឹមត្រូវ ។ ដូច្នេះ សូមបង្ហាញនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើប្រធាន «នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង» នេះ។

# មាតិកា


ទំព័រ

សេចក្តីផ្តើម ........................................ ១

**ជំពូកទី ១**

**វិវាទនៃកិច្ចសន្យា**

**ផ្នែកទី ១ លក្ខណៈទូទៅនៃវិវាទកិច្ចសន្យា** ........................................ ៤

កថាខណ្ឌទី ១ និយមន័យនៃវិវាទកិច្ចសន្យា ........................................ ៤

កថាខណ្ឌទី ២ វិវាទកិច្ចសន្យាបុគ្គល ........................................ ៤

កថាខណ្ឌទី ៣ វិវាទកិច្ចសន្យារួម ........................................ ៤

**ផ្នែកទី ២ ប្រភពនៃវិវាទកិច្ចសន្យា** ........................................ ៥

កថាខណ្ឌទី ១ ការភាន់ច្រឡំ ........................................ ៥

កថាខណ្ឌទី ២ ការឆបោក ........................................ ៥

កថាខណ្ឌទី ៣ ការផ្តល់ព័ត៌មានមិនពិត ........................................ ៦

កថាខណ្ឌទី ៤ ការរំលោភបំពានលើស្ថានភាព ........................................ ៦

កថាខណ្ឌទី ៥ ការគម្រាមកំហែង ........................................ ៧

កថាខណ្ឌទី ៦ អំពើកេងយកចំណេញហួសហេតុ ........................................ ៧

កថាខណ្ឌទី ៧ បបនីយផ្លូវចិត្ត ........................................ ៧

កថាខណ្ឌទី ៨ ការបង្ហាញឆន្ទៈមិនពិត ........................................ ៨

កថាខណ្ឌទី ៩ កម្មវត្ថុខុសច្បាប់ ........................................ ៨

កថាខណ្ឌទី ១០ គ្មានតម្លៃតបស្នង ឬ តម្លៃតបស្នងមិនគ្រប់ ........................................ ៩

កថាខណ្ឌទី ១១ អលទ្ធភាពអនុវត្តកាតព្វកិច្ច ........................................ ៩

កថាខណ្ឌទី ១២ អសមត្ថជន ........................................ ៩

**ជំពូកទី ២**

**សមត្ថកិច្ចតុលាការសាលាដំបូងលើវិវាទកិច្ចសន្យា**

**ផ្នែកទី ១ សាលាដំបូង និង រចនាសម្ព័ន្ធ** ........................................ ១០

កថាខណ្ឌទី ១ សាលាដំបូង ........................................ ១០

កថាខណ្ឌទី ២ រចនាសម្ព័ន្ធតុលាការដោះស្រាយវិវាទកិច្ចសន្យា ........................................ ១០

**ផ្នែកទី ២ សមត្ថកិច្ចសាលាជម្រះក្តីវិវាទកិច្ចសន្យា** ............ ១១
កថាខណ្ឌទី ១ សមត្ថកិច្ចលំនៅឋានភាគី ............ ១១
កថាខណ្ឌទី ២ សមត្ថកិច្ចទ្រព្យសម្បត្តិភាគី ............ ១២
កថាខណ្ឌទី ៣ សមត្ថកិច្ចកំណត់ក្នុងខចែងកិច្ចសន្យា ............ ១២
កថាខណ្ឌទី ៤ សមត្ថកិច្ចតាមការចាំបាច់របស់ភាគីកិច្ចសន្យា ............ ១២
**ផ្នែកទី ៣ ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជិតចិត្ត** ............ ១៣
កថាខណ្ឌទី ១ ការដកហូតសមត្ថកិច្ចជំនុំជម្រះ ............ ១៣
កថាខណ្ឌទី ២ បណ្តឹងជិតចិត្តចៅក្រម ឬ ក្រឡាបញ្ជី ............ ១៤
កថាខណ្ឌទី ៣ ការដកខ្លួនរបស់ចៅក្រម ឬ ក្រឡាបញ្ជី ............ ១៤

## ជំពូកទី ៣

## នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា

**ផ្នែកទី ១ ភាគីក្នុងបណ្តឹងវិវាទកិច្ចសន្យា** ............ ១៥
កថាខណ្ឌទី ១ សមត្ថភាពភាគីក្នុងបណ្តឹងវិវាទកិច្ចសន្យា ............ ១៥
កថាខណ្ឌទី ២ សមត្ថភាពភាគីក្នុងការធ្វើសកម្មភាពបណ្តឹងវិវាទកិច្ចសន្យា ............ ១៥
កថាខណ្ឌទី ៣ ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹងវិវាទកិច្ចសន្យា ............ ១៦
កថាខណ្ឌទី ៤ ការទទួលបន្តនូវបណ្តឹងវិវាទកិច្ចសន្យា ............ ១៦
កថាខណ្ឌទី ៥ សិទ្ធិរបស់ភាគីក្នុងសវនាការ ............ ១៧
**ផ្នែកទី ២ អ្នកតំណាង** ............ ១៨
កថាខណ្ឌទី ១ អ្នកតំណាងដែលច្បាប់បានកំណត់ ............ ១៩
កថាខណ្ឌទី ២ អ្នកតំណាងដោយអាណត្តិ ............ ១៩
កថាខណ្ឌទី ៣ អ្នកជំនួយ ............ ២០
**ផ្នែកទី ៣ បណ្តឹង** ............ ២១
កថាខណ្ឌទី ១ របៀបសរសេរពាក្យបណ្តឹង ............ ២១
កថាខណ្ឌទី ២ កម្មវត្ថុនៃបណ្តឹង ............ ២២
កថាខណ្ឌទី ៣ ការដាក់ពាក្យបណ្តឹង ............ ២២
កថាខណ្ឌទី ៤ ការចាត់ចែងពាក្យបណ្តឹង ............ ២២
កថាខណ្ឌទី ៥ អានុភាពនៃការដាក់ពាក្យបណ្តឹង ............ ២៣
**ផ្នែកទី ៤ ប្រាក់ប្រដាប់ក្តី** ............ ២៣
កថាខណ្ឌទី ១ ប្រភេទនៃប្រាក់ប្រដាប់ក្តី ............ ២៣
កថាខណ្ឌទី ២ បន្ទុកនៃប្រាក់ប្រដាប់ក្តី ............ ២៥

កថាខណ្ឌទី ៣ ប្រាតិភោគលើប្រាក់ប្រដាប់ក្តី ........ ២៥
កថាខណ្ឌទី ៤ ការជួយសង្គ្រោះលើបណ្តឹង ........ ២៦
**ផ្នែកទី ៥ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យានៅសាលាដំបូង** ........ ២៦
កថាខណ្ឌទី ១ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៧
កថាខណ្ឌទី ២ ការទាញហេតុផលដោយផ្ទាល់មាត់ ........ ៣១
**ផ្នែកទី ៦ ភស្តុតាង** ........ ៣៤
កថាខណ្ឌទី ១ គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង ........ ៣៤
កថាខណ្ឌទី ២ ការត្រួតពិនិត្យភស្តុតាង ........ ៣៥
កថាខណ្ឌទី ៣ ការថែរក្សាការពារភស្តុតាង ........ ៣៩
**ផ្នែកទី ៧ បណ្តឹងទាស់** ........ ៤១
កថាខណ្ឌទី ១ បណ្តឹងទាស់ ........ ៤១
កថាខណ្ឌទី ២ របៀបធ្វើបណ្តឹងទាស់ ........ ៤១
កថាខណ្ឌទី ៣ អានុភាពនៃបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់ ........ ៤២
**ផ្នែកទី ៨ បណ្តឹងតប** ........ ៤៣
កថាខណ្ឌទី ១ បណ្តឹងតប ........ ៤៤
កថាខណ្ឌទី ២ លក្ខខណ្ឌនៃបណ្តឹងតប ........ ៤៤
កថាខណ្ឌទី ៣ ការចាត់ចែងបណ្តឹងតប ........ ៤៤
**ផ្នែកទី ៩ ការបញ្ចប់វិវាទកិច្ចសន្យានៅសាលាដំបូង** ........ ៤៥
កថាខណ្ឌទី ១ ការបញ្ចប់វិវាទកិច្ចសន្យាដោយសាលក្រមចុងក្រោយ ........ ៤៥
កថាខណ្ឌទី ២ ការបញ្ចប់វិវាទកិច្ចសន្យាដោយមិនចេញសាលក្រម ........ ៤៦
កថាខណ្ឌទី ៣ ការបញ្ចប់វិវាទកិច្ចសន្យាដោយស្វ័យប្រវត្តិ ........ ៤៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

-សេចក្តីសន្និដ្ឋាន ........ ៤៩
-អនុសាសន៍ ........ ៤៩
-ឯកសារយោង
-ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## • លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ មានប្រទេសជាច្រើននៅលើសកលលោកមានការរីកចម្រើនយ៉ាងខ្លាំងលើ ការដោះស្រាយវិវាទកិច្ចសន្យា ជាពិសេសប្រទេសដែលមានការអភិវឌ្ឍ និង ប្រទេសកំពុងអភិវឌ្ឍន៍។ ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសទាំងឡាយនោះផងដែរ ដោយមានការចូលរួមយ៉ាងសកម្មក្នុងការប្រែក្លាយខ្លួន ទៅជាប្រទេសមួយ ដែលស្ថិតក្នុងការអភិវឌ្ឍសមត្ថភាពនៃការដោះស្រាយវិវាទកិច្ចសន្យាតាមប្រព័ន្ធតុលាការ។

ឆ្លើយតបតម្រូវការបច្ចុប្បន្ន ក្នុងការដោះស្រាយវិវាទកិច្ចសន្យា សារណាបញ្ចប់ការសិក្សានេះនឹងលើកយកការសិក្សាស្រាវជ្រាវមួយ ដែលបង្ហាញពី នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាមួយដោយតុលាការនៅសាលាដំបូង។ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា គឺវាមានការចាំបាច់បំផុតសម្រាប់វិស័យពាណិជ្ជកម្ម អាជីវកម្ម ជាដើម។

ដូច្នេះហើយ បានជា សារណាបញ្ចប់ការសិក្សានេះ ធ្វើការសិក្សាស្រាវជ្រាវលើ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង។

## • ចំណោទបញ្ហានៃការស្រាវជ្រាវ

នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា ជាសេចក្តីត្រូវការបំផុតរបស់គូភាគីវិវាទ ក្នុងវិស័យពាណិជ្ជកម្ម អាជីវកម្ម ជាដើម ដោយមិនអាចខ្វះបានឡើយ ។ ដោយមើលឃើញអំពីបញ្ហាទាំងអស់នេះហើយ ទើបសារណាបញ្ចប់ការសិក្សានេះ ធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ " នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង " ដើម្បីចង់ដឹងអំពីៈ

ប្រភពនៃការកកើតវិវាទកិច្ចសន្យា ?

តើនីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូងដូចម្តេចខ្លះ ?

## • គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីបង្ហាញពីនីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូងក្នុងប្រទេសកម្ពុជា ដោយផ្តោតទៅលើចំណុចសំខាន់ៗ មួយចំនួនដូចជា ៖

ដើម្បីស្វែងយល់ពីច្បាប់ពាក់ព័ន្ធនីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា។

ដើម្បីស្វែងយល់ពីវិវាទកិច្ចសន្យា។

ដើម្បីស្វែងយល់ពីយន្តការនៃការដោះស្រាយវិវាទកិច្ចសន្យា

ដើម្បីស្វែងយល់ពីសមត្ថកិច្ចពាក់ព័ន្ធនឹងការដោះស្រាយវិវាទកិច្ចសន្យា។

• **ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើការដោះស្រាយវិវាទកិច្ចសន្យាតាមប្រព័ន្ធតុលាការនៅសាលាដំបូងក្នុងប្រទេសកម្ពុជា តាមរយៈសាលក្រមរដ្ឋប្បវេណីរបស់តុលាការសាលាដំបូង និង ក្រមរដ្ឋប្បវេណី ០៨ ធ្នូ ២០០៧ និង ក្រមនីតិវិធីរដ្ឋប្បវេណី ០៦ កក្កដា ២០០៦។

តាមរយៈការណែនាំពីលោកសាស្ត្រាចារ្យ និង សាកសួរមន្ត្រីនៅសាលាដំបូង

តាមរយៈការសាកសួរពីលោកមេធាវី

តាមរយៈការសិក្សាទៅលើឯកសារផ្សេងៗ ដោយខ្លួនឯង។

• **វិធីសាស្ត្រនៃការស្រាវជ្រាវ**

វិធីសាស្ត្រនៃការស្រាវជ្រាវបានប្រើប្រាស់ ដើម្បីធ្វើការស្រាវជ្រាវសរសេរសារណាបញ្ចប់ការសិក្សានេះរួមមាន៖

**វិធីសាស្ត្រប្រមូលទិន្នន័យ**

មុននឹងសម្រេចចិត្តរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះ ដោយបានធ្វើការសន្សំ និងប្រមូលទិន្នន័យតាមបែបគុណភាព ហើយព័ត៌មានដែលបានប្រមូលមកសរសេរសំអាងលើទិន្នន័យមួយ និងទិន្នន័យបន្ទាប់បន្សំជាទិន្នន័យដែលបានមកពីការសាកសួរអ្នកច្បាប់ ឬមេធាវីដោយផ្ទាល់។ ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវនេះប្រកបដោយជោគជ័យទាមទារនូវតម្រូវការទិន្នន័យជាច្រើនយកមកវិភាគដែលក្នុងនោះមានទិន្នន័យទីមួយ និងទិន្នន័យទីពីរ។

**ទិន្នន័យទីមួយ**

ទិន្នន័យចម្បងដែលបានប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ត្រូវបានប្រមូលមកតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម៖

ការជួបសាកសួរដោយផ្ទាល់ជាមួយមន្ត្រីសាលាដំបូង

សាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង

**ទិន្នន័យទីពីរ**

ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យទាក់ទងទៅនឹងប្រធានបទ ដែលស្វែងរកបានតាមរយៈ៖

សៀវភៅឯកសារក្នុងបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សៀវភៅដែលពាក់ព័ន្ធនានាទៀត។

**វិធីសាស្ត្រវិភាគវិភាគទិន្នន័យ**

ទិន្នន័យដែលប្រមូលបានធ្វើការវិភាគបែបគុណភាពដោយផ្តោតយកទៅលើខ្លឹមសារអត្ថបទ និង ទិន្នន័យចម្បងៗសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ព្រមទាំងធ្វើបទសម្ភាសន៍ជាមួយលោកមេធាវី និងមន្ត្រីពាក់ព័ន្ធ។

- **រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

សារណាបញ្ចប់ការសិក្សានេះចែកចេញជា ៣ ជំពូកគឺ

សេចក្តីផ្តើម

ជំពូកទី ១ វិវាទកិច្ចសន្យា

ជំពូកទី ២ តុលាការមានសមត្ថកិច្ចលើសាលាជម្រះក្តីវិវាទកិច្ចសន្យា

ជំពូកទី ៣ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី ១
# វិវាទនៃកិច្ចសន្យា

## ផ្នែកទី ១ លក្ខណៈទូទៅនៃវិវាទកិច្ចសន្យា

វិវាទកិច្ចសន្យា ជាវិវាទមួយដែលកើតឡើងរវាងភាគីកិច្ចសន្យា និងភាគីកិច្ចសន្យា។វិវាទកិច្ចសន្យានេះកើតឡើងមកពីភាគីនៃកិច្ចសន្យាមិនប្រតិបត្តិតាមកិច្ចសន្យា ឬ អលទ្ធភាពក្នុងការអនុវត្តកិច្ចសន្យា មិនគោរពសិទ្ធិរបស់ភាគីម្ខាងទៀតហើយមិនអនុវត្តនូវករណីយកិច្ចរបស់ខ្លួន ដោយសេចក្តីសុចរិត ហេតុដូច្នេះ ហើយទើបនាំឱ្យកើតមាននូវវិវាទកិច្ចសន្យានានា និយមន័យនៃវិវាទកិច្ចសន្យា (កថាខណ្ឌទី ១) វិវាទកិច្ចសន្យាបុគ្គល (កថាខណ្ឌទី ២) វិវាទកិច្ចសន្យារួម (កថាខណ្ឌទី ៣) ។

### កថាខណ្ឌទី ១ និយមន័យនៃវិវាទកិច្ចសន្យា

វិវាទ = ដំណើរទាស់ទែងគ្នា, ដំណើរឈ្លោះប្រកែកគ្នា[១]។

កិច្ចសន្យា = គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬរំលត់នូវកាតព្វកិច្ច[២]។

***និយមន័យ***

វិវាទកិច្ចសន្យា គឺជាដំណើរការទាស់ទែងគ្នា ឬ ដំណើរការឈ្លោះប្រកែកគ្នា ដែលកើតឡើងដោយកិរិយារបស់បុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈមិនត្រូវគ្នាក្នុងការបន្ត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច។

### កថាខណ្ឌទី ២ វិវាទកិច្ចសន្យាបុគ្គល

វិវាទកិច្ចសន្យាបុគ្គល ជាវិវាទដែលកើតមានឡើងរវាងនិយោជក និង កម្មករនិយោជិតម្នាក់[៣] វិវាទនេះ ជាវិវាទកិច្ចសន្យាការងារជារឿយៗ តែងកើតមកពីភាគីណាមួយនៃភាគីកិច្ចសន្យាការងារនោះ ដែលមិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា។

រូបវន្តបុគ្គល វិវាទកិច្ចសន្យាកើតមានឡើងរវាង រូបវន្តបុគ្គល និង រូបវន្តបុគ្គល។

នីតិបុគ្គល វិវាទកិច្ចសន្យាកើតមានឡើងរវាង នីតិបុគ្គល និង នីតិបុគ្គល។

---

[១] ជួន ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១១ គ.ស.១៩៦៧ ភ្នំពេញ ទំព័រ ៨៩៦

[២] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[៣] មាត្រា ៣០០ នៃច្បាប់ស្តីពីការងារ ១៣ មីនា ១៩៩៧

**កថាខណ្ឌទី ៣ វិវាទកិច្ចសន្យារួម**

វិវាទកិច្ចសន្យារួម ជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬ ច្រើននាក់ និងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងលក្ខខណ្ឌកិច្ចសន្យា[៤] ដែលនិយោជកមានការរំលោភបំពានសិទ្ធិ កេងប្រវ័ញ្ចកម្លាំងពលកម្មរបស់កម្មករនិយោជិត។

**ផ្នែកទី ២ ប្រភពនៃវិវាទកិច្ចសន្យា**

វិវាទនៃកិច្ចសន្យាជារឿយៗតែងកើតឡើងពី ការភាន់ច្រឡំ (កថាខណ្ឌទី ១) ការឆបោក (កថាខណ្ឌទី ២) ការគម្រាមកំហែង (កថាខណ្ឌទី ៣) ការផ្តល់ព័ត៌មានមិនពិត (កថាខណ្ឌទី ៤) ការរំលោភបំពានលើស្ថានភាព (កថាខណ្ឌទី ៥) អំពើកេងយកចំណេញហួសហេតុ (កថាខណ្ឌទី ៦) បបនីយផ្លូវចិត្ត (កថាខណ្ឌទី ៧) ការបង្ហាញឆន្ទៈមិនពិត (កថាខណ្ឌទី ៨) កម្មវត្ថុខុសច្បាប់ (កថាខណ្ឌទី ៩) គ្មានតម្លៃតបស្នង ឬ តម្លៃតបស្នងមិនគ្រប់ (កថាខណ្ឌទី ១០) អលទ្ធភាពអនុវត្តកាតព្វកិច្ច (កថាខណ្ឌទី ១១) អសមត្ថជន (កថាខណ្ឌទី ១២)។

**កថាខណ្ឌទី ១ ការភាន់ច្រឡំកិច្ចសន្យា**

ការភាន់ច្រឡំនៃកិច្ចសន្យា គឺជាការភាន់ច្រឡំដែលកើតឡើងរវាងភាគីកិច្ចសន្យា និង ភាគីកិច្ចសន្យា។ ការភាន់ច្រឡំនៃកិច្ចសន្យាមាន ការភាន់ច្រឡំទៅលើកម្មវត្ថុ និង ការភាន់ច្រឡំទៅលើសារធាតុជាសារវន្តនៃវត្ថុ ឬ បុគ្គលនៃកិច្ចសន្យានោះ ភាគីដែលបានភាន់ច្រឡំអាចសុំកែប្រែ ឬ លុបចោលកិច្ចសន្យានោះបាន ទោះបីជាភាគីមិនដឹងពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលកិច្ចសន្យានោះបានដែរ ការលុបចោលនូវកិច្ចសន្យាភាន់ច្រឡំក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិតហើយគ្មានកំហុសអំពីការភាន់ច្រឡំមិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះ បានឡើយ[៥]។

**កថាខណ្ឌទី ២ ការឆបោក**

ការឆបោកកិច្ចសន្យា គឺជាអំពើបន្លំនូវកិច្ចសន្យាចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយដោយការប្រើឧបាយកលទុច្ចរិតដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនោះ ឬ តតិយជនជាភាគីនៃកិច្ចសន្យាដូចជា ភាគី ឬតតិយជនមានគោលបំណងឆបោក សកម្មភាពឆបោកនោះ ត្រូវបានទទួល

[៤] មាត្រា ៣០២ នៃច្បាប់ស្តីពីការងារ ១៣ មីនា ១៩៩៧

[៥] មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

ស្គាល់ថា ខុសច្បាប់ អ្នកបង្ហាញឆន្ទៈបានភាន់ច្រឡំ ដោយសារសកម្មភាពឆបោក អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយមានវិការៈដោយសារតែការភាន់ច្រឡំនោះ ភាគី ឬ តតិយជនអាចលុបចោលកិច្ចសន្យាដោយការឆបោកនោះ ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចលុបកិច្ចសន្យាចំពោះតតិយជននោះបានឡើយ[៦]។

**កថាខណ្ឌទី ៣ ការផ្តល់ព័ត៌មានមិនពិត**

ការផ្តល់ព័ត៌មានមិនពិត គឺជាការផ្តល់នូវព័ត៌មានខុសពីការពិតចំពោះវត្ថុកិច្ចសន្យាដែលមាន ឬ ហេតុដែលភាគីបានលើកឡើងដែលជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យា គឺខុសការពិត។ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីនោះខុសការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើ ភាគីនោះដឹងថា មិនមែនជាការពិតខ្លួននឹងមិនបង្ហាញឆន្ទៈទេ ប្រសិនបើភាគីនៃកិច្ចសន្យាដែលបានបង្ហាញការណ៍មិនពិតនោះមានកំហុសក្នុងការផ្តល់នូវព័ត៌មានមិនពិតនេះ ភាគីនៃកិច្ចសន្យានោះត្រូវទទួលខុសត្រូវការសងសំណងការខូចខាត ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយផ្អែកលើការផ្តល់នូវព័ត៌មានមិនពិត ។ ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ[៧]។

**កថាខណ្ឌទី ៤ ការរំលោភបំពានលើស្ថានភាព**

ការរំលោភបំពានលើស្ថានភាព សំដៅទៅលើករណីដែលភាគីកិច្ចសន្យា បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីកិច្ចសន្យាម្ខាងទៀត កំពុងជួបប្រទះនូវការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬសង្គម ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងៗទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបតបាន ។ នៅក្នុងករណីនេះ ភាគីកិច្ចសន្យាដែលបានរំលោភបំពានលើស្ថានភាព មិនត្រូវបានគេចាត់ទុកថា បានគំរាមកំហែងឡើយ ព្រោះភាគីកិច្ចសន្យា មិនបានប្រើវិធានការណ៍បង្ខំ។ ក៏ប៉ុន្តែ ដើម្បីបង្កើតជាការរំលោភបំពានលើស្ថានភាព វាមានភាពចាំបាច់ដែលភាគីនៃកិច្ចសន្យាម្ខាងទៀតឆ្លៀតឱកាសនៃស្ថានភាពទន់ខ្សោយរបស់អ្នកបង្ហាញឆន្ទៈ ។ ប្រសិនបើ ភាគីនៃកិច្ចសន្យាដែលបាន

[៦] មាត្រា ៣៨៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[៧] មាត្រា ៣៨៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

បង្ហាញឆន្ទៈដោយសារការរំលោភលើស្ថានភាពពីភាគីកិច្ចសន្យាម្ខាងទៀត ភាគីកិច្ចសន្យានោះអាចលុបចោលកិច្ចសន្យាបាន ។ ប៉ុន្តែ ការលុបចោលកិច្ចសន្យានេះ មិនអាចតតាំងចំពោះតតិយជនសុចរិត និង គ្មានកំហុស អំពីការរំលោភបំពានលើស្ថានភាពបានឡើយ[៨]។

**កថាខណ្ឌទី ៥ ការគម្រាមកំហែង**

ការគម្រាមកំហែង សំដៅទៅលើករណីដែល អ្នកបង្ហាញឆន្ទៈបានបង្ហាញនូវឆន្ទៈរបស់ខ្លួនដែលផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារភាពភ័យខ្លាចភាគីកិច្ចសន្យាម្ខាងទៀត ឬ តតិយជន។ ប្រសិនបើការបង្ហាញឆន្ទៈនោះមានវិការៈ ច្បាប់អនុញ្ញាតឱ្យអ្នកបង្ហាញឆន្ទៈលុបចោលនូវកិច្ចសន្យានេះបាន។បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលកិច្ចសន្យានោះបាន ដោយផ្អែកលើការគម្រាមកំហែងរបស់ភាគីម្ខាងទៀត ឬ តតិយជននោះ[៩]។

**កថាខណ្ឌទី ៦ អំពើកេងយកចំណេញហួសហេតុ**

អំពើកេងយកចំណេញហួសហេតុ ដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាង សេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះ អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[១០]។

**កថាខណ្ឌទី ៧ ឋបនីយផ្លូវចិត្ត**

ឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដោយភាគីដែលដឹងខ្លួនថា ការបង្ហាញឆន្ទៈតាមការជាក់ស្តែងរបស់ខ្លួនមានលក្ខណៈខុសគ្នានឹងឆន្ទៈពិតប្រាកដរបស់ខ្លួន ។ ភាគីដែលបានបង្ហាញឆន្ទៈខ្លួនឯងផ្ទាល់នោះ បានដឹងយ៉ាងពិតប្រាកដថា ការបង្ហាញនូវឆន្ទៈដែលបានបង្ហាញនោះមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនឡើយ ហើយខ្លួននៅតែសម្រេចចិត្តធ្វើការបង្ហាញទៀត ។ ប្រសិនបើ កិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញនូវឆន្ទៈដែលភាគីដឹងខ្លួនថា ខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀត ក៏ដឹងថាការបង្ហាញឆន្ទៈ

[៨] មាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[៩] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[១០] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

នោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះ អាចបដិសេធការអនុវត្តកិច្ចសន្យាបាន[១១]។

### កថាខណ្ឌទី ៨ ការបង្ហាញឆន្ទៈមិនពិត

ការបង្ហាញឆន្ទៈមិនពិត សំដៅលើកិច្ចសន្យា ដែលធ្វើឡើងដោយផ្អែកលើការបង្ហាញនូវឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើងដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ជាមោឃៈ។ មោឃភាពនៃកិច្ចសន្យា មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ជាជនសុចរិត ហើយគ្មានកំហុសធ្ងន់ធ្ងរដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានទេ។ ក្នុងករណីដែលមានការភាន់ច្រឡំ តតិយជនត្រូវមានភាពសុចរិត និង គ្មានកំហុសដើម្បីលុបចោលកិច្ចសន្យាដោយសារការភាន់ច្រឡំ។ ប៉ុន្តែ ក្នុងករណីនៃការបង្ហាញឆន្ទៈមិនពិត ពីព្រោះស្ទើរតែគ្មានភាពចាំបាច់ការពារបុគ្គលដែលបង្ហាញឆន្ទៈមិនពិត អ្នកបង្ហាញនូវឆន្ទៈមិនពិតមិនអាចអះអាងមោឃភាពចំពោះតតិយជនបានឡើយ លើកលែងតែតតិយជនបានដឹងអំពីការបង្ហាញឆន្ទៈមិនពិត ឬ មិនដឹងការបង្ហាញឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ[១២]។

### កថាខណ្ឌទី ៩ កម្មវត្ថុខុសច្បាប់

ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ ក្នុងករណីដូចជា អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ និងអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈទំនៀមទម្លាប់ល្អ។ប្រសិនបើ អត្ថន័យកិច្ចសន្យានោះមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឲ្យខូចនូវសេចក្តីសង្ឃឹមសមហេតុផលរបស់គូភាគីទេនោះ មានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ[១៣]។

[១១] មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[១២] មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[១៣] មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

**កថាខណ្ឌទី ១០ គ្មានតម្លៃតបស្នង ឬ តម្លៃតបស្នងមិនគ្រប់**

កិច្ចសន្យាដែលបានធ្វើរួចហើយជាមួយ និង ភាគីកិច្ចសន្យាម្ខាងទៀត ប៉ុន្តែ កិច្ចសន្យានោះគ្មានតម្លៃតបស្នងដល់ភាគីកិច្ចសន្យា ឬ មានតម្លៃតបស្នងដល់ភាគីកិច្ចសន្យាដែរ ប៉ុន្តែ តម្លៃតបស្នងនោះមិនមានតុល្យភាពនឹងកម្មវត្ថុនៃកិច្ចសន្យាដែលភាគីនោះបានព្រមព្រៀងគ្នា នៅមុនពេលធ្វើកិច្ចសន្យាជាមួយគ្នា ក្នុងការផ្តល់ឱ្យនូវតម្លៃតបស្នងដល់ភាគីនៃកិច្ចសន្យាម្ខាងទៀតនោះ។

**កថាខណ្ឌទី ១១ អលទ្ធភាពអនុវត្តកាតព្វកិច្ច**

ភាគីកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលភាគីបង្កើតកិច្ចសន្យានោះ មកក៏ដោយក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពអនុវត្តនោះឡើយ។ ប្រសិនបើ ភាគីដែលបានធ្វើកិច្ចសន្យាដោយជឿជាក់ថា ខ្លឹមសារនៃកិច្ចសន្យាអាចអនុវត្តបានបំពេញលក្ខខណ្ឌនៃការភាន់ច្រឡំ នោះភាគីអាចលុបចោលកិច្ចសន្យា ដោយយកមូលហេតុថា មានការភាន់ច្រឡំ។ ប្រសិនបើភាគីកិច្ចសន្យាមានភាពចម្រូងចម្រាស់គ្នា ហើយមានទំហំនៃការខូចខាតក្នុងករណីនេះ ត្រូវកម្រិតត្រឹមការសងនៃការខូចខាតផលប្រយោជន៍នោះដែលកើតឡើងដោយសារភាគីជឿជាក់ថាមានកិច្ចសន្យា ឬមានវិសាលភាពដល់ការសងការខូចខាតផលប្រយោជន៍ដែលអាចទទួលពីការអនុវត្តកិច្ចសន្យានោះដល់ភាគីម្ខាងទៀត[១៤] ។ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដូចជាភាគីអនុវត្តមិនកើត ឬ មិនបាន (មានកំហុស) និង ច្បាប់ហាមឃាត់។

**កថាខណ្ឌទី ១៣ អសមត្ថជន**

អសមត្ថជន គឺជាជនដែលគ្មានសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន[១៥]ឬ ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជនជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ[១៦] ។ អសមត្ថជនទាំងអស់នោះរួមមាន៖

អនីតិជនគ្មានអត្តាធីនភាព សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប៉ុន្តែគ្មានអត្តាធីនភាព។

នីតិជនវិបល្លាស្មារតី ជនដែលមានស្មារតីមិនប្រក្រតី ឬជនដែលមានបញ្ហាសរសៃប្រសាទ។

---

[១៤] មាត្រា ៣៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[១៥] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

[១៦] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧

# ជំពូកទី ២

# សមត្ថកិច្ចតុលាការសាលាដំបូងលើវិវាទកិច្ចសន្យា

## ផ្នែកទី ១ សាលាដំបូង និង រចនាសម្ព័ន្ធ

សាលាដំបូង (កថាខណ្ឌទី ១) រចនាសម្ព័ន្ធសវនាការវិវាទកិច្ចសន្យា (កថាខណ្ឌទី ២)

### កថាខណ្ឌទី ១ សាលាដំបូង

សាលាដំបូង គឺជាតុលាការខេត្ត ក្រុង រាជធានី ដែលតាំងនៅក្នុង ខេត្ត ក្រុង រាជធានី ណាមានសមត្ថកិច្ចដោះស្រាយតែរឿងក្តីវិវាទកិច្ចសន្យាទាំងឡាយណាដែលកើតឡើងនៅក្នុងរង្វង់ដែនដីនៃខេត្ត ក្រុង រាជធានី ដែលតុលាការនោះតាំងនៅតែប៉ុណ្ណោះ[១៧]។

### កថាខណ្ឌទី ២ រចនាសម្ព័ន្ធសវនាការវិវាទកិច្ចសន្យា

រចនាសម្ព័ន្ធសវនាការរឿងក្តីវិវាទកិច្ចសន្យាដែលមានទឹកប្រាក់ចំនួនក្រោម ៥.០០០.០០០ (ប្រាំលាន) រៀលចុះ នៅសាលាដំបូង (តុលាការ ខេត្ត ក្រុង រាជធានី )។




រចនាសម្ព័ន្ធសវនាការរឿងក្តីវិវាទកិច្ចសន្យាដែលមានទឹកប្រាក់ចំនួន ៥.០០០.០០០ រៀលឡើង នៅសាលាដំបូង (តុលាការ ខេត្ត ក្រុង រាជធានី )។

[១៧] ការផ្សាយរបស់សមាគម អាដហុក ផ្លូវនៃបណ្តឹង ភ្នំពេញ ២០០៨ ទំព័រ ១




**ផ្នែកទី ២ សមត្ថកិច្ចមានសិទ្ធិលើបណ្តឹងវិវាទកិច្ចសន្យា**

សមត្ថកិច្ចមានសិទ្ធិលើបណ្តឹងវិវាទកិច្ចសន្យា គឺជាសមត្ថកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹង លំនៅឋាន ទ្រព្យសម្បត្តិ និង មុខជំនួញរបស់ភាគីកិច្ចសន្យាមាន សមត្ថកិច្ចលំនៅឋានភាគី (កថាខណ្ឌទី ១) សមត្ថកិច្ចទ្រព្យសម្បត្តិភាគី (កថាខណ្ឌទី ២) សមត្ថកិច្ចកំណត់ក្នុងខចែងកិច្ចសន្យា (កថាខណ្ឌទី ៣) និង សមត្ថកិច្ចតាមការចាំបាច់របស់ភាគី (កថាខណ្ឌទី ៤)។

**កថាខណ្ឌទី ១ សមត្ថកិច្ចលំនៅឋានភាគី**

សមត្ថកិច្ចលំនៅឋានរបស់ភាគីកិច្ចសន្យា (ចុងចម្លើយ) ឬ លំនៅឋានរបស់ចុងចម្លើយ ទីសំណាក់ លំនៅឋានចុងក្រោយ ទីតាំងនៃទីស្នាក់ការ ទីកន្លែងអាជីវកម្មជាចម្បង លំនៅឋានរបស់អ្នកតំណាងប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា[១៨]។បណ្តឹងវិវាទកិច្ចសន្យាអាចដាក់មកសមត្ថកិច្ចដែលមានការពាក់ព័ន្ធដូចរៀបរាប់ខាងលើនេះបាន ដោយយកពាក្យបណ្តឹងទៅដាក់នៅសាលាដំបូងនោះ ពីព្រោះ សាលាដំបូងនោះមានសមត្ថកិច្ចស្ថិតនៅលើទីកន្លែងរបស់ភាគីកិច្ចសន្យា (ចុងចម្លើយ) ជាសមត្ថកិច្ចមានសិទ្ធិលើវិវាទកិច្ចសន្យា។

[១៨] មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

**កថាខណ្ឌទី ២ សមត្ថកិច្ចទ្រព្យសម្បត្តិភាគី**

សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ទៅតាមទ្រព្យសម្បត្តិភាគី គឺជាសមត្ថកិច្ចដែលទទួលស្គាល់ដោយកំណត់ទៅតាមទីកន្លែងដែលបានអនុវត្តកាតព្វកិច្ច ឬសមត្ថកិច្ចទីកន្លែងនៃទ្រព្យសម្បត្តិដោយគិតដល់ខ្លឹមសារនៃរឿងក្តី ជាដើម។ ការកំណត់សមត្ថកិច្ចបែបនេះ គឺផ្តល់ឱកាសឱ្យជនដែលមានវិវាទកិច្ចសន្យាដាក់ពាក្យបណ្តឹង អាចជ្រើសរើសតុលាការណាមួយ ក្នុងចំណោមតុលាការទាំងនោះដោយសេរីបាន និង ទំនាក់ទំនងទីកន្លែងរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គល និង សកម្មភាពជំនួញរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលនោះ ធ្វើឱ្យមាននូវភាពងាយស្រួលក្នុងការឆ្លើយតបរបស់ចុងចម្លើយសម្រួលការវិនិច្ឆ័យបណ្តឹង តាមរយៈចំណាងទៅនឹងទីកន្លែងនៃភស្តុតាងនៃអំពើអនីត្យានុកូល[១៩]។

**កថាខណ្ឌទី ៣ សមត្ថកិច្ចកំណត់ក្នុងខចែងកិច្ចសន្យា**

សមត្ថកិច្ចកំណត់ក្នុងកិច្ចសន្យា គឺជាសមត្ថកិច្ចដែលបានកើតឡើងដោយភាគីកិច្ចសន្យា និង ភាគីកិច្ចសន្យា ដែលបានព្រមព្រៀងគ្នាកំណត់នៅពេលដែលភាគីបានបង្កើតកិច្ចសន្យា ហើយកំណត់នូវសមត្ថកិច្ចនោះក្នុង ខ ចែងកិច្ចសន្យា ប្រសិនបើ ភាគីកិច្ចសន្យាមានវិវាទកិច្ចសន្យា សមត្ថកិច្ចដែលចែងក្នុង ខ កិច្ចសន្យានោះមានអត្ថិភាពមុនសមត្ថកិច្ច លំនៅឋាន សមត្ថកិច្ចទ្រព្យសម្បត្តិ។

**កថាខណ្ឌទី ៤ សមត្ថកិច្ចតាមការចាំបាច់របស់ភាគីកិច្ចសន្យា**

សមត្ថកិច្ចតាមការចាំបាច់របស់ភាគីកិច្ចសន្យា គឺជាការបែងចែក ឬ ជ្រើសរើសនូវសមត្ថកិច្ចទៅតាមការចាំបាច់របស់ភាគីកិច្ចសន្យា ដូចជា តុលាការមានសមត្ថកិច្ចមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីបានដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តី មិនអាចកំណត់បានដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ចដោយដីកាសម្រេចតាមពាក្យសុំរបស់ភាគីវិវាទ[២០]។ ដោយមូលហេតុ ដូចជា ចៅក្រមនៅសាលាជម្រះក្តីនោះដកខ្លួនចេញ ដោយមានមូលហេតុតាមច្បាប់នាំឱ្យការដោះស្រាយរឿងក្តីមិនអាចធ្វើទៅបាន ឬទីតាំងតុលាការទទួលរងដោយគ្រោះធម្មជាតិ ឬដោយសារអំពើអនីត្យានុកូលកើតឡើងនៅកន្លែងដែលមិនអាចកំណត់ថា ជាដែនសមត្ថកិច្ចនៃតុលាការណាមួយ។

[១៩] មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[២០] មាត្រា ១២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

## ផ្នែកទី ៣ ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្ដឹងជិតចិត្ត

ការដកហូតនូវសមត្ថកិច្ចជំនុំជម្រះ និង បណ្ដឹងជិតចិត្តធ្វើឡើងចំពោះចៅក្រម ឬ ក្រឡាបញ្ជីទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសំណុំរឿងវិវាទកិច្ចសន្យានោះ ការដកហូតសមត្ថកិច្ចជំនុំជម្រះ (កថាខណ្ឌទី ១) បណ្ដឹងជិតចិត្តចៅក្រម ឬ ក្រឡាបញ្ជី (កថាខណ្ឌទី ២) និង ការដកខ្លួនរបស់ចៅក្រម ឬ ក្រឡាបញ្ជី (កថាខណ្ឌទី ៣)។

### កថាខណ្ឌទី ១ ការដកហូតសមត្ថកិច្ចជំនុំជម្រះ

ការដកហូតសមត្ថកិច្ចជំនុំជម្រះ គឺជារបបមួយដែលដកហូតចៅក្រម ពីការបំពេញនូវមុខងាររបស់ខ្លួន ដោយស្វ័យប្រវត្តិតាមផ្លូវច្បាប់ ក្នុងករណីដែលមានហេតុប៉ះពាល់ដល់សមភាពដោយធ្ងន់ធ្ងរ។ ក្នុងករណីដែលមានមូលហេតុដូចជា៖

១) កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្ដី។

២) កាលណាចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬញាតិពន្ធក្នុងថ្នាក់ទី ៣(បី) ឬ អតីតញាតិពន្ធក្នុងថ្នាក់ទី ៣(បី) របស់ភាគីណាមួយ។

៣) កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ។

៤) កាលណាចៅក្រមដែលទទួលនូវបន្ទុករឿងក្ដី ធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។

៥) កាលណាចៅក្រមបានធ្វើជាសាក្សី ឬ ធ្វើជាអ្នកជំនាញក្នុងរឿងក្ដី។

៦) កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ធ្វើជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្ដី។

៧) កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដី មជ្ឈត្តករ (អ្នកសម្របសម្រួល) ចំពោះរឿងក្ដី ឬ បានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងការជំនុំជម្រះលើកទី ១ ដែលបានឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានធ្វើឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី[២១]។ ក្នុងករណីដូចមានមូលហេតុនៃការដកហូតនូវសមត្ថកិច្ច ដែលបានកំណត់ដូចខាងលើនេះ តុលាការត្រូវសម្រេចការដកហូតសមត្ថកិច្ចជំនុំជម្រះពីចៅក្រមនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ ប្រសិនបើមានមូលហេតុទាំងនេះកើតមានឡើង តែគេមិនបានដឹងហើយបាន

[២១] មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ចេញសាលក្រម ឬ សាលដីកាភាគីអាចទាមទារឱ្យលុបចោលនូវសាលក្រម ឬ សាលដីកានោះ ដោយបណ្តឹងសាទុក្ខ ឬ បណ្តឹងសុំឱ្យជំនុំជម្រះសាជាថ្មីបាន[២២]។

**កថាខណ្ឌទី ២ បណ្តឹងជិតចិត្តចៅក្រម ឬ ក្រឡាបញ្ជី**

បណ្តឹងជិតចិត្តចៅក្រម ឬ ក្រឡាបញ្ជី គឺជាបណ្តឹងដែលសុំមិនឱ្យចៅក្រម ឬ ក្រឡាបញ្ជីណាម្នាក់អនុវត្តមុខងាររបស់ខ្លួន ក្នុងករណីមានកាលៈទេសៈ ដែលអាចបណ្តាលឱ្យមានការលម្អៀងក្នុងការជម្រះក្តីរបស់ចៅក្រម ឬក្រឡាបញ្ជីនោះ ភាគីអាចប្តឹងជិតចិត្តចៅក្រម ឬក្រឡាបញ្ជីនោះបាន[២៣]។ ក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬ បានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជិតចិត្តចៅក្រមនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលភាគីនោះមិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជិតចិត្ត ឬ ករណីដែលមូលហេតុនៃបណ្តឹងជិតចិត្តបានកើតឡើងនៅពេលក្រោយ[២៤]។

**កថាខណ្ឌទី ៣ ការដកខ្លួនរបស់ចៅក្រម ឬ ក្រឡាបញ្ជី**

ការដកខ្លួនរបស់ចៅក្រម គឺជារបបមួយដែលចៅក្រមលាលែងពីការបំពេញមុខងាររបស់ខ្លួន ដោយទទួលនូវការអនុញ្ញាតពីប្រធានតុលាការដែលខ្លួនស្ថិតនៅក្រោម ក្នុងករណីដែលបានដឹងខ្លួនឯងថា មានមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬ ការប្តឹងជិតចិត្ត[២៥] ។ បញ្ញត្តិច្បាប់ស្តីពីការដកហូតនូវសមត្ថកិច្ចជំនុំជម្រះ ការប្តឹងជិតចិត្ត ការដកខ្លួនរបស់ចៅក្រម និង ក្រឡាបញ្ជី ត្រូវបានធ្វើដោយតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនោះក៏ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះក្រឡាបញ្ជី[២៦]។

---

[២២] មាត្រា ២៨៥ កថាខណ្ឌទី ១ចំណុច ក,ខ មាត្រា ៣០៧កថាខណ្ឌទី ១ ចំណុច ក,ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[២៣] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៧០ និង មាត្រា ២៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២៤] មាត្រា ២៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[២៥] មាត្រា ២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[២៦] មាត្រា ៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

# ជំពូកទី ៣
# នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា

## ផ្នែកទី ១ ភាគីក្នុងបណ្តឹងវិវាទកិច្ចសន្យា

ភាគី គឺជាបុគ្គលដែលបានដាក់នូវពាក្យបណ្តឹងស្នើសុំឱ្យតុលាការ ដោះស្រាយវិវាទរបស់ខ្លួន នឹងបុគ្គលម្ខាងទៀត ដែលមានការពាក់ព័ន្ធនឹងវិវាទនោះ[២៧] ឬ អ្នកដែលបានទាមទារនូវសាលក្រម ក្នុងនាមរបស់ខ្លួន ដើម្បីឱ្យតុលាការដោះស្រាយវិវាទព្រមទាំងជនដែលត្រូវទាមទារឱ្យចង្អុលឈ្មោះ នៅក្នុងសាលក្រមនោះក្នុងនាមជាភាគីម្ខាងទៀត។ ភាគី ហៅថា ដើមចោទ និង ចុងចម្លើយក្នុងការ ជំនុំជម្រះក្តីលើកទី ១ ។ សមត្ថភាពភាគីក្នុងបណ្តឹងវិវាទកិច្ចសន្យា (កថាខណ្ឌទី ១) សមត្ថភាពភាគី ក្នុងការធ្វើសកម្មភាពបណ្តឹង (កថាខណ្ឌទី ២) ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង (កថាខណ្ឌទី ៣) ការទទួលបន្តនូវបណ្តឹង (កថាខណ្ឌទី ៤) សិទ្ធិរបស់ភាគីក្នុងសវនាការ (កថាខណ្ឌទី ៥)។

### កថាខណ្ឌទី ១ សមត្ថភាពភាគីក្នុងបណ្តឹងវិវាទកិច្ចសន្យា

សមត្ថភាពភាគី គឺជាបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិ និង ករណីយកិច្ច មានសមត្ថភាពធ្វើសកម្មភាព ឬអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងទើបអាចក្លាយជាភាគីដើមចោទ ឬ ចុងចម្លើយនៅក្នុងបណ្តឹងវិវាទកិច្ចសន្យាបាន[២៨] ។ ប្រសិនបើ ភាគីម្ខាង ឬ ទាំងសងខាងមានកង្វះ សមត្ថភាព តុលាការត្រូវចេញសាលក្រមលើកពាក្យបណ្តឹងនោះចោល ដោយសារតែលក្ខខណ្ឌមិន គ្រប់គ្រាន់តាមច្បាប់កំណត់។ ក្នុងករណីដែល ភាគីពុំមានសមត្ថភាពជាភាគីក៏ដោយ តែបើតុលាការ មិនបានដឹងហើយបានចេញសាលក្រម ភាគីអាចប្តឹងទាមទារលុបចោលសាលក្រមនោះបាន ដោយ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ពេលដែលសាលក្រមនោះមិនទាន់ចូលជាស្ថាពរ ។ ក៏ប៉ុន្តែ ក្រោយពេលចូលជាស្ថាពរ មិនអាចទាមទារឱ្យលុបចោលដោយបណ្តឹងសុំជំនុំជម្រះសាជាថ្មីបានទេ (មិនចាំបាច់សុំលុបចោល ក៏ពុំមានអានុភាពដែរ)។

### កថាខណ្ឌទី ២ សមត្ថភាពភាគីក្នុងការធ្វើសកម្មភាពបណ្តឹងវិវាទកិច្ចសន្យា

សមត្ថភាពភាគីក្នុងការធ្វើសកម្មភាពបណ្តឹង ជាសមត្ថភាពរបស់បុគ្គលដែលអាចយល់ដឹង នឹងចេះវិនិច្ឆ័យបាននូវភាពខុសត្រូវដែលកើតចេញពីទង្វើរបស់ខ្លួន ហើយជាម្ចាស់សិទ្ធិ និងករណីយ

[២៧] ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ឆ្នាំ ២០០៧ ទំព័រ ៧៦

[២៨] មាត្រា ៣២កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា០៦កក្កដា ២០០៦

កិច្ច ហើយត្រូវតែជានីតិជន ឬ អនីតិជនដែលទទួលបាននូវអត្តាធីនភាពអាចធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់ក្នុងការដាក់ពាក្យបណ្ដឹងបាន ឬ តាមរយៈការពឹងពាក់មេធាវី ហើយប្រគល់សិទ្ធិនោះឱ្យទៅមេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្លួន។ ចំណែកឯជនដែលមានវិបល្លាសស្មារតី និងអនីតិជនគ្មានអត្តាធីនភាព អាចធ្វើបណ្ដឹងបានតាមរយៈមាតាបិតា ឬ អាណាព្យាបាលរបស់ពួកគេ។ មាតាបិតា ឬ អាណាព្យាបាលអាចធ្វើបណ្ដឹងជំនួសអសមត្ថជនបានក្នុងនាមការពារផលប្រយោជន៍របស់ជននៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។ រីឯនីតិបុគ្គលវិញ ក៏ត្រូវបានធ្វើបណ្ដឹង តាមរយៈអ្នកតំណាងរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍រួមរបស់នីតិបុគ្គលនោះ។

**កថាខណ្ឌទី ៣ ការចូលរួមអន្តរាគមន៍ក្នុងបណ្ដឹងវិវាទកិច្ចសន្យា**

ការចូលរួមអន្តរាគមន៍ក្នុងបណ្ដឹង គឺជាការចូលរួមរបស់តតិយជនដែលមានការទាក់ទងផលប្រយោជន៍តាមផ្លូវច្បាប់អំពីលទ្ធផលនៃបណ្ដឹងរបស់អ្នកផ្សេង ចូលរួមក្នុងបណ្ដឹងនោះ ដើម្បីជួយឱ្យភាគីណាមួយឱ្យបានឈ្នះបណ្ដឹង អ្នកចូលរួមអន្តរាគមន៍ មិនមែនជាភាគីនៃបណ្ដឹង និងមិនមានផលប្រយោជន៍ឯករាជ្យក្នុងបណ្ដឹងនោះទេ គ្រាន់តែមានបំណងការពារនូវផលប្រយោជន៍របស់ខ្លួន[២៩]។ តតិយជនត្រូវដាក់ពាក្យសុំចូលរួមអន្តរាគមន៍ដោយធ្វើបណ្ដឹងជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ទៅតុលាការដែលខ្លួននឹងត្រូវធ្វើសកម្មភាពបណ្ដឹងតាមការចូលរួមអន្តរាគមន៍ ឬ អាចធ្វើឡើងព្រមគ្នាជាមួយនឹងសកម្មភាពបណ្ដឹងដែលអ្នកចូលរួមអន្តរាគមន៍បានធ្វើការអះអាងអំពីអង្គហេតុ ឬ ស្នើសុំឱ្យសាកសួរសាក្សី ឬ ករណីអ្នកត្រូវគេចូលរួមអន្តរាគមន៍ចាញ់ក្តី អាចធ្វើបណ្ដឹងឧទ្ធរណ៍បាន។ ពាក្យសុំចូលរួមជួយអន្តរាគមន៍ក្នុងបណ្ដឹងត្រូវបញ្ជាក់ថា ចូលរួមសម្រាប់ភាគីណាមួយនៃបណ្ដឹង និង បញ្ជាក់អំពីមូលហេតុការចូលរួមអន្តរាគមន៍ឱ្យច្បាស់លាស់[៣០]។

**កថាខណ្ឌទី ៤ ការទទួលបន្តនូវបណ្ដឹងវិវាទកិច្ចសន្យា**

ការទទួលបន្តនូវបណ្ដឹង គឺជាការទទួលបន្តនូវសិទ្ធិ និង ឋានៈជាភាគីនៃបណ្ដឹងដោយតតិយជន បន្ទាប់ពីបណ្ដឹងនោះបានចាត់ការដោយសាមីនៃបណ្ដឹងនោះ ទទួលនូវមរណភាព ការរលត់នីតិបុគ្គលដែលជាភាគីដោយការរួមបញ្ចូលនីតិបុគ្គល ការទទួលបន្ទុកក្នុងការធ្វើបណ្ដឹងដោយផ្អែកលើលក្ខណសម្បត្តិដែលបានកំណត់ដូចជា អ្នកប្រតិបត្តិមតកសាសន៍ជាដើម បានបាត់បង់នូវលក្ខណសម្បត្តិនោះ បណ្ដឹងត្រូវបានធ្វើដោយភាគីដែលត្រូវបានជ្រើសរើសហើយភាគីដែលត្រូវបានជ្រើស

[២៩] មាត្រា ៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៣០] មាត្រា ៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

រើសនោះនឹងបន្តនូវបណ្តឹងក្នុងនាមជាភាគីនៃបណ្តឹង[៣១] ។ ការទទួលបន្តនេះ គឺទទួលបន្តទាំងលទ្ធផលនៃសកម្មភាពបណ្តឹងដែលបានធ្វើដោយភាគីពីមុនមកក៏ត្រូវបានបន្តឱ្យទៅភាគីថ្មីដែរ ទោះបីជាសកម្មភាពនោះមានផលប្រយោជន៍ ឬ គ្មានផលប្រយោជន៍ដល់ភាគីថ្មីនេះក៏ដោយ។ ប្រសិនបើ អង្គហេតុដែលជាមូលហេតុនៃការទទួលបន្តបណ្តឹងដូចជា មរណភាពរបស់ភាគីជាដើមបានកើតឡើង ការទទួលបន្តនូវបណ្តឹងនឹងកើតឡើងដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់មានសកម្មភាពរបស់តុលាការ ឬរបស់ភាគីទេ ដោយសារបុគ្គលដែលទទួលបន្តបណ្តឹងនោះ មិនមែនជាភាគីពីមុនមកទេ ដូច្នេះ មិនអាចត្រៀមដើម្បីធ្វើសកម្មភាពចាំបាច់តាមផ្លូវនីតិវិធីនៃបណ្តឹងភ្លាមៗ បានទេ ។ ក្នុងករណីដែលអង្គហេតុជាមូលហេតុនៃការទទួលបន្តបណ្តឹងកើតឡើង នីតិវិធីនៃបណ្តឹងត្រូវផ្អាកដោយស្វ័យប្រវត្តិនេះ គឺជាការផ្អាកនីតិវិធីបណ្តឹង[៣២]។ នីតិវិធីបណ្តឹងដែលបានផ្អាក នឹងត្រូវបន្តឡើងវិញ បើមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹងពីអ្នកទទួលបន្ត ឬ ពីភាគីម្ខាងទៀត[៣៣] ឬ ក្នុងករណីដែលតុលាការចេញដីកាសម្រេចបង្គាប់ឱ្យបន្តនីតិវិធីនៃបណ្តឹង[៣៤]។

**កថាខណ្ឌទី ៥ សិទ្ធិរបស់ភាគីក្នុងសវនាការ**

សិទ្ធិរបស់ភាគីក្នុងពេលសវនាការរឿងវិវាទកិច្ចសន្យាមានដូចខាងក្រោម៖

សុំសួរសាក្សី ឬ ភាគីម្ខាងទៀត ឬ មេធាវី តាមរយៈចៅក្រម

សុំឱ្យចៅក្រមផ្អាកសវនាការ ដើម្បីរកភស្តុតាងបន្ថែមទៀត បើភស្តុតាងនោះទើបតែដឹងនូវពេលជជែកក្នុងសវនាការ។

សុំផ្អាកសវនាការ ដើម្បីឱ្យតុលាការធ្វើកោសលវិច័យអ្វីមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ខ្លួន។

សុំដកពាក្យបណ្តឹងវិញ។

សុំប្តឹងបន្ថែម (ទាមទារការប្រាក់ ទាមទារជំងឺចិត្តដែលកន្លងមកខ្លួនពុំបាននឹកនាប្តឹងផ្តល់)

ប្តឹងតប (បណ្តឹងតប)។

---

[៣១] មាត្រា ១៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៣២] មាត្រា ១៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៣៣] មាត្រា ១៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៣៤] មាត្រា ១៧៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

សុំបង្អង់រឿងទុកមួយអន្លើ។

សុំទទួលនូវសំណើរបស់ភាគីម្ខាងទៀត ដោយមានលក្ខខណ្ឌដូចជា សុខចិត្តសងរំលោះរហូតដល់ថ្ងៃ...ខែ...ឆ្នាំ...បើដល់ពេលកំណត់ហើយមិនសងសុខចិត្តបង់ជំងឺចិត្តចំនួន...។

ផ្ទេរសិទ្ធិឱ្យមេធាវី ឬ បងប្អូនប្តឹងជំនួស។

ផ្ទេរសិទ្ធិឱ្យមេធាវី ឡើងតុលាការតទល់ជាមួយដើមបណ្តឹង ឬ ចុងចម្លើយជំនួសខ្លួន។

សុំជំទាស់ការលើកឡើងរបស់ភាគីម្ខាងទៀត និង សាក្សី ប្រសិនបើការលើកឡើងនោះមិនត្រឹមត្រូវ។

សុំឱ្យចៅក្រមចេញដីការក្សាការពារទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀតជាបណ្តោះអាសន្នដើម្បីទុកធានាសំណង។

សុំកែប្រែចម្លើយដែលបានឆ្លើយច្រឡំកន្លងមក។

សុំជំទាស់ការលើកឡើងរបស់មេធាវី ទោះមេធាវីកាន់ខាងខ្លួន ឬកាន់ខាងភាគីម្ខាងទៀតក៏ដោយ។

សុំឱ្យតុលាការដាក់គុកបង្ខំរូបកាយកូនបំណុលបើគ្មានប្រាក់សង។

សិទ្ធិប្តឹងឧទ្ធរណ៍។

សិទ្ធិប្តឹងសាទុក្ខ និង សិទ្ធិផ្សេងៗទៀត តាមច្បាប់កំណត់និងតាមការព្រមព្រៀងរបស់ភាគីម្ខាងទៀត[៣៥]។

## ផ្នែកទី ២ អ្នកតំណាង

អ្នកតំណាង គឺជាបុគ្គលដែលមាននូវលក្ខណសម្បត្តិគ្រប់គ្រាន់ទៅតាមផ្លូវច្បាប់កំណត់ ឬឋានៈជាអ្នកតំណាងតាមផ្លូវច្បាប់ ដែលបានទទួលនូវសិទ្ធិតំណាង ជាសិទ្ធិដែលអ្នកតំណាងអាចធ្វើកិច្ចការជំនួសម្ចាស់សិទ្ធិ ហើយបង្កើតអានុភាពឱ្យម្ចាស់សិទ្ធិ[៣៦]។ អ្នកតំណាងធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬភាគីម្ខាងទៀត ដោយផ្អែកលើឆន្ទៈរបស់ខ្លួនក្នុងនាមជាភាគីជំនួស ហើយអានុភាពនៃការធ្វើសកម្មភាពបណ្តឹង ឬ ទទួលសកម្មភាពបណ្តឹងនោះនឹងមាន

[៣៥] ហ៊ីង ធីឫទ្ធិ អត្ថាធិប្បាយច្បាប់ ភាគ ៣ ក្នុងរឿងរដ្ឋប្បវេណី សម្រាប់ប្រជារាស្ត្រសាមញ្ញ ភ្នំពេញ បោះពុម្ពលើកទី ២ ឆ្នាំ ២០០៧ ទំព័រ ៤៨ ៤៩

[៣៦] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៨៧ និងទំព័រ ៩៣

ទៅលើភាគី។ អ្នកតំណាងដែលច្បាប់បានកំណត់ (កថាខណ្ឌទី ១) អ្នកតំណាងដោយអាណត្តិ ឬកិច្ចសន្យា (កថាខណ្ឌទី ២) និងអ្នកជំនួយ (កថាខណ្ឌទី ៣)។

**កថាខណ្ឌទី ១ អ្នកតំណាងដែលច្បាប់បានកំណត់**

អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាបុគ្គលដែលបានទទួលសិទ្ធិតំណាងដោយច្បាប់[៣៧] ឬ តាមរយៈសេចក្ដីសម្រេចរបស់តុលាការមិនមែនផ្អែកលើឆន្ទៈរបស់សាមីភាគីទេ[៣៨] ។ អ្នកតំណាងដែលច្បាប់បានកំណត់ ធ្វើសកម្មភាពបណ្ដឹងជំនួសជនដែលគ្មានសមត្ថភាព ដើម្បីផលប្រយោជន៍ជននោះ។ប្រសិនបើ គ្មានអ្នកតំណាងដូចច្បាប់បានកំណត់ ឬមានអ្នកតំណាង ប៉ុន្តែ អនុវត្តសិទ្ធិនោះមិនបាន ហើយភាគីម្ខាងទៀតមានភាពចាំបាច់ក្នុងការធ្វើបណ្ដឹងជាបន្ទាន់ អាចដាក់ពាក្យស្នើសុំទៅតុលាការដែលទទួលពាក្យបណ្ដឹងនោះ ឱ្យតុលាការធ្វើការជ្រើសតាំងអ្នកតំណាងពិសេស ហើយការជ្រើសតាំងអ្នកតំណាងពិសេសនេះសម្រាប់តែករណីចាំបាច់បុណ្ណោះ ដើម្បីការពារផលប្រយោជន៍[៣៩] ឬ ថែរក្សាភស្តុតាងភាគីម្ខាងទៀតបាន[៤០]។

**កថាខណ្ឌទី ២ អ្នកតំណាងដោយអាណត្តិ**

អ្នកតំណាងដោយអាណត្តិ គឺជាអ្នកដែលបានទទួលនូវសិទ្ធិតំណាងនោះដោយផ្អែកលើឆន្ទៈរបស់ភាគី ដើម្បីធ្វើសកម្មភាពក្នុងនីតិវិធីចំពោះមុខតុលាការក្នុងនាមជាម្ចាស់សិទ្ធិ[៤១] ហើយត្រូវធ្វើការបញ្ជាក់ដោយលាយលក្ខណ៍អក្សរថា ខ្លួនមានសិទ្ធិតំណាងដោយអាណត្តិនោះ[៤២]។ទោះជាភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹងក៏ដោយ តាមធម្មតាច្រើនតែពុំមានចំណេះដឹងផ្នែកច្បាប់ដែលចាំបាច់ដើម្បីធ្វើសកម្មភាពបណ្ដឹងឱ្យមានប្រសិទ្ធិភាព និង ឱ្យបានសមស្របទេ ដូច្នេះហើយ ត្រូវរកអ្នកទទួលសិទ្ធិដោយអាណត្តិពីភាគី ចំពោះរឿងក្ដីនីមួយៗ ឱ្យធ្វើសកម្មភាពបណ្ដឹងនោះ ។ អ្នកតំណាង

[៣៧] ទីស្ដីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៩៤

[៣៨] មាត្រា ១៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៣៩] មាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៤០] មាត្រា ១៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៤១] ទីស្ដីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៨៧ និង៩៤

[៤២] មាត្រា ៣៥ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ដោយអាណត្តិ មានតែមេធាវីទេ លើកលែងតែមានការកំណត់ផ្សេង ក្នុងករណីដែលមានជនក្រៅពីមេធាវី បានធ្វើសកម្មភាពបណ្តឹងក្នុងនាមជាអ្នកតំណាងដោយអាណត្តិ ជាគោលការណ៍ គឺជាអំពើខុសនឹងច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ព័ន្ធរបស់អ្នកនោះក្នុងបណ្តឹង។ សកម្មភាពដែលអ្នកនោះបានធ្វើពុំមានសុពលភាពទេ ប៉ុន្តែ ប្រសិនបើភាគីបានផ្តល់សច្ចានុមតិសកម្មភាពនោះនឹងមានសុពលភាព។ ជនក្រៅពីមេធាវីអាចធ្វើជាអ្នកតំណាងដោយអាណត្តិបាន បើតាមក្រមនីតិវិធីរដ្ឋប្បវេណីដូចជា៖

ក) ករណីដែលទទួលស្គាល់ឱ្យតតិយជនក្រៅពីមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគីបានលុះត្រាតែមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ដទៃផ្សេងទៀត។

ខ) ករណីដែលភាគីជារដ្ឋ ឬ ស្ថាប័នរដ្ឋជាដើម ជាភាគី ហើយមានការកំណត់ឱ្យមន្ត្រីស្ថាប័ននោះធ្វើជាអ្នកតំណាងរបស់ស្ថាប័ននោះនិង

គ) ករណីដែលតុលាការអនុញ្ញាតឱ្យតតិយជនពិសេសក្រៅពីមេធាវី ធ្វើជាអ្នកតំណាងក្នុងរឿងក្តីដែលទឹកប្រាក់នៃកម្មវត្ថុនៃបណ្តឹងនោះតិចជាង ១.០០០.០០០ (មួយលាន) រៀល[៤៣]។

### កថាខណ្ឌទី ៣ អ្នកជំនួយ

អ្នកជំនួយ ជាអ្នកជួយភាគីដោយការចូលរួមក្នុងសវនាការជាមួយភាគី ឬ អ្នកតំណាងដោយអាណត្តិ ដោយមានការអនុញ្ញាតពីតុលាការ តុលាការមានឆន្ទានុសិទ្ធិអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យមានអ្នកជំនួយ បើភាគី ឬ អ្នកតំណាងដោយអាណត្តិ មានបំណងឱ្យអ្នកជំនួយចូលរួមក្នុងតុលាការជាមួយខ្លួន អ្នកនោះត្រូវទទួលការអនុញ្ញាតពីតុលាការ ហើយតុលាការអាចលុបចោលការអនុញ្ញាតនោះនៅពេលណាក៏បានដែរ។ អ្នកជំនួយនេះ ជាទូទៅ ត្រូវបានប្រើប្រាស់ក្នុងករណីដែលភាគី ឬអ្នកតំណាងដោយអាណត្តិខ្វះនូវចំណេះដឹងខាងផ្នែកបច្ចេកទេស ដូចជា បណ្តឹងទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឬ ករណីដែលភាគីជាជនពិការក្នុងការនិយាយ ឬ ក្នុងការស្តាប់ ហើយត្រូវមានអ្នកជំនួយដើម្បីបន្ថែមសេចក្តីថ្លែងការណ៍របស់ជននោះ។ ក៏ប៉ុន្តែ សេចក្តីថ្លែងការណ៍ដែលអ្នកជំនួយបានធ្វើ ប្រសិនបើភាគី ឬ អ្នកតំណាងដោយអាណត្តិមិនបានលុបចោល ឬ ធ្វើការកែតម្រូវភ្លាមៗ ទេនោះ អានុភាពនៃសេចក្តីថ្លែងការណ៍នោះ នឹងធ្លាក់ទៅលើសាមីភាគី ដូចសេចក្តីថ្លែងការណ៍របស់សាមីភាគី ឬ អ្នកតំណាងដោយអាណត្តិដែរ[៤៤]។

[៤៣] មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

## ផ្នែកទី ៣ បណ្តឹង

បណ្តឹង គឺជាអំណាចដែលច្បាប់ទទួលស្គាល់សម្រាប់ភាគីវិវាទកិច្ចសន្យា ភាគីមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីទាមទារអោយមានការគោរពសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់គេ ។ ចំពោះបណ្តឹងវិវាទកិច្ចសន្យាវិញ គឺធ្វើឡើងដោយផ្អែកទៅតាមសិទ្ធិដែលមានទៅលើចលនវត្ថុ ឬ អចលនវត្ថុ ឬ លើរូបបុគ្គលដែលជាគោលបំណងនៃការប្តឹងនោះ ដូចជា ដី ផ្ទះ កង់ ឡាន ម៉ូតូ ឬ ប្តឹងសុំអោយអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាជាដើម។

ភាគីវិវាទកិច្ចសន្យាអ្នកប្តឹង ត្រូវធ្វើបណ្តឹងដាក់ជូនទៅប្រធានតុលាការរដ្ឋប្បវេណីនៅសាលាដំបូងរាជធានី ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ អោយបានទាន់ពេលវេលាកាល បើធ្វើឡើងក្រោយរយៈពេលច្បាប់កំណត់ បណ្តឹងនោះមិនអាចទទួលបានឡើយ[៤៤]។ ភាគីអាចទាមទារទៅតុលាការនូវការសុំឱ្យទទួលស្គាល់សិទ្ធិទាមទាររបស់ខ្លួន ក៏ប៉ុន្តែ ប្រសិនបើ ម្ចាស់សិទ្ធិប្តឹងនោះមានការរំលោភច្បាប់ ចៅក្រមអាចសម្រេចសេចក្តីឱ្យសងជម្ងឺចិត្តទៅខាងចុងចម្លើយជាជនរងគ្រោះដោយការប្តឹងចោទដោយរំលោភនោះ[៤៦]។ របៀបសរសេរពាក្យបណ្តឹង (កថាខណ្ឌទី ១) កម្មវត្ថុនៃបណ្តឹង (កថាខណ្ឌទី ២) ការដាក់ពាក្យបណ្តឹង (កថាខណ្ឌទី ៣) ការចាត់ចែងពាក្យបណ្តឹង (កថាខណ្ឌទី ៤) និង អានុភាពនៃបណ្តឹង (កថាខណ្ឌទី ៥)។

### កថាខណ្ឌទី ១ របៀបសរសេរពាក្យបណ្តឹង

របៀបសរសេរពាក្យបណ្តឹង គឺជារបៀបមួយដែលពន្យល់ប្រាប់អំពីពាក្យពេចន៍ដែលនិយាយលាតត្រដាងដោយការសរសេរពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ អំពីគោលបំណងនៃការប្តឹងសុំទាមទារនូវអ្វីមួយតាមរយៈតុលាការ ។ បណ្តឹងអាចធ្វើផ្ទាល់មាត់នៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចក៏បាន អាចធ្វើជាលិខិតលាយលក្ខអក្សរដាក់ជូនមន្ត្រីមានសមត្ថកិច្ចក៏បាន ប៉ុន្តែ ជាគោលការណ៍ដើមបណ្តឹងត្រូវសរសេរពាក្យបណ្តឹងជាលាយលក្ខអក្សរដែលត្រូវបញ្ជាក់អោយបានច្បាស់លាស់អំពី៖

**ក) រូបវន្តបុគ្គល**

ឈ្មោះ អ្នកប្តឹង (ឈ្មោះក្នុងបញ្ជីជាតិ និង ឈ្មោះហៅក្រៅបញ្ជីជាតិបើមាន) ភេទ អាយុ ឬ ឆ្នាំកំណើត សញ្ជាតិ មុខរបរ ទីលំនៅដើមបណ្តឹងបច្ចុប្បន្នអចិន្ត្រៃយ៍ ឬ មិនអចិន្ត្រៃយ៍។

---

[៤៤] មាត្រា ៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៤៥] សមាគម អាដហុក ផ្លូវនៃបណ្តឹង ភ្នំពេញ ឆ្នាំ ២០០៨ ទំព័រ ៤

[៤៦] ជូន ស៊ុនឡេង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ ឆ្នាំ ២០០១ ២០០២ ទំព័រ ៤

ឈ្មោះ អ្នកត្រូវប្ដឹង (ឈ្មោះក្នុងបញ្ជីជាតិ និង ឈ្មោះហៅក្រៅបញ្ជីជាតិបើមាន) ភេទ អាយុ ឬ ឆ្នាំកំណើត សញ្ជាតិ មុខរបរទីលំនៅដើមបណ្ដឹងបច្ចុប្បន្នអចិន្ត្រៃយ៍ ឬ មិនអចិន្ត្រៃយ៍ និង ព័ត៌មានផ្សេងៗទៀត ដែលអាចបញ្ជាក់បានអំពីភិនភាគរបស់ចុងចម្លើយ។

**ខ) នីតិបុគ្គល**

នាមករណ៍ ទីស្នាក់ការបំពេញការងារ (ផ្ទះលេខ......ផ្លូវលេខ.......) អត្តសញ្ញាណពេញលេញរបស់តំណាង ព័ត៌មានសំខាន់សម្រាប់កំណត់ភិនភាគចុងចម្លើយអោយបានត្រឹមត្រូវ។

**កថាខណ្ឌទី ២ កម្មវត្ថុនៃបណ្ដឹង**

កម្មវត្ថុត្រូវកំណត់អោយបានច្បាស់លាស់ នៅក្នុងពាក្យបណ្ដឹងដែលមានទំនាក់ទំនងកាតព្វកិច្ចនៃកិច្ចសន្យា ការបញ្ជាក់ក្នុងកម្មវត្ថុបណ្ដឹងមាន ដូចជា បណ្ដឹងទាមទារសុំឱ្យអនុវត្តកាតព្វកិច្ច និង ជួសជុលព្យសនកម្មជាដើម ពីបុគ្គលណាមួយដែលជាកូនបំណុលរបស់ខ្លួន។ កម្មវត្ថុនៃបណ្ដឹងត្រូវអោយស្របច្បាប់ ស្របប្រពៃណី ហើយមិនត្រូវជាកម្មវត្ថុនៃបណ្ដឹងដែលត្រូវបានតុលាការជំនុំជម្រះជាស្ថាពររួចហើយឡើយ[៤៧]។

**កថាខណ្ឌទី ៣ ការដាក់ពាក្យបណ្ដឹង**

ពាក្យបណ្ដឹងវិវាទកិច្ចសន្យាដែលធ្វើឡើងដោយភាគីកិច្ចសន្យា ត្រូវយកមកដាក់ជូនប្រធានតុលាការសាលាដំបូងដែលមានសមត្ថកិច្ច ដូចដែលបានកំណត់នូវក្នុងពាក្យបណ្ដឹងដែលភាគីធ្វើជាលាយលក្ខណ៍អក្សរនោះ តាមរយៈក្រឡាបញ្ជីនាយក ឬ ក្រឡាបញ្ជីដែលជាអ្នកទទួលពាក្យបណ្ដឹង។ នៅពេលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធដែលមានចំនួនទឹកប្រាក់ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង ពន្ធនេះហៅថា ពន្ធដាក់ពាក្យបណ្ដឹងសុំ[៤៨] ។

**កថាខណ្ឌទី ៤ ការចាត់ចែងពាក្យបណ្ដឹង**

ក្រឡាបញ្ជីនាយក ឬ ក្រឡាបញ្ជីជាអ្នកទទួលពាក្យបណ្ដឹងបោះត្រាលើពាក្យបណ្ដឹង និង ចុះកាលបរិច្ឆេទបញ្ជាក់ថ្ងៃ ខែ ឆ្នាំ ដែលបានទទួលពាក្យបណ្ដឹងនោះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា បណ្ដឹងនោះដាក់នៅពេលណា បន្ទាប់មកចុះលេខរៀងនៅក្នុងសៀវភៅបញ្ជីពាក្យបណ្ដឹង ដើម្បីបែងចែកសំណុំរឿង។ ក្រឡាបញ្ជីនាយក ឬ ក្រឡាបញ្ជី ត្រូវបែងចែកសំណុំរឿងនៃបណ្ដឹងទៅតាមចៅក្រមដែលទទួលបន្ទុករឿងក្ដីនោះ ទៅតាមលំដាប់នៃការបែងចែករឿងក្ដីដែលបានកំណត់ដោយ

[៤៧] សមាគម អាដហុក ផ្លូវនៃបណ្ដឹង ភ្នំពេញ ឆ្នាំ ២០០៨ ទំព័រ ១៦

[៤៨] មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ដីកាសម្រេចប្រចាំឆ្នាំជាមុនដោយប្រធានតុលាការ[៤៩]។

**កថាខណ្ឌទី ៥ អានុភាពនៃការដាក់ពាក្យបណ្តឹង**

អានុភាពនៃការដាក់ពាក្យបណ្តឹង ជាផលគតិយុត្តនៃការទាមទារដែលកើតចេញពីការបញ្ជូនពាក្យបណ្តឹងបានទៅដល់ចុងចម្លើយ ហើយតុលាការកំណត់កាលបរិច្ឆេទចេញដីកាកោះហៅគូភាគីមកធ្វើការជំនុំជម្រះ និង ចេញសាលក្រមនឹងកើតឡើងរវាងដើមចោទ និង ចុងចម្លើយជាកំណត់ករណីនេះ ហៅថា ការចាត់ចែងលើបណ្តឹង។ អានុភាពនៃការដាក់ពាក្យបណ្តឹងនាំឱ្យបង្កើតអានុភាពសំខាន់ជាងគេ គឺការហាមឃាត់មិនឱ្យមានការធ្វើបណ្តឹងជាន់គ្នា ការហាមមិនឱ្យដាក់ពាក្យបណ្តឹងក្រោយដែលមានខ្លឹមសារដូចគ្នានឹងបណ្តឹងដែលបានដាក់មុន ហើយជាបណ្តឹងកំពុងត្រូវបានតុលាការចាត់ការ [៥០]។ប្រសិនបើមានបណ្តឹងជាន់គ្នា តុលាការអាចលើកចោលនូវបណ្តឹងនោះដោយសាលក្រមដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[៥១]។

**ផ្នែកទី ៤ ប្រាក់ប្រដាប់ក្តី**

ប្រាក់ប្រដាប់ក្តី គឺជាប្រាក់ពន្ធ ឬ សោហ៊ុយ ដែលភាគីត្រូវបង់នៅពេលធ្វើសកម្មភាពបណ្តឹងសម្រាប់ចាត់ការរឿងក្តីរបស់ខ្លួនឱ្យមានដំណើរការ ទៅតុលាការតាមបញ្ញត្តិច្បាប់ធរមាន[៥២]។ ប្រភេទនៃប្រាក់ប្រដាប់ក្តី (កថាខណ្ឌទី ១) បន្ទុកនៃប្រាក់ប្រដាប់ក្តី (កថាខណ្ឌទី ២) ប្រាតិភោគលើប្រាក់ប្រដាប់ក្តី (កថាខណ្ឌទី ៣) និង ការជួយសង្គ្រោះលើបណ្តឹង (កថាខណ្ឌទី ៤)។

**កថាខណ្ឌទី ១ ប្រភេទនៃប្រាក់ប្រដាប់ក្តី**

ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ០៧០៦/ ០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ បានកំណត់អំពីប្រាក់ប្រដាប់ក្តី ប្រាក់ប្រដាប់ក្តីត្រូវបានបែងចែកជា ៣ ប្រភេទគឺ ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និង ប្រាក់ប្រដាប់ក្តីភាគី។

១)ពន្ធដាក់ពាក្យសុំ គឺជាប្រាក់ប្រដាប់ក្តីមួយប្រភេទដែលតុលាការតម្រូវឱ្យភាគីបង់នៅពេល

[៤៩] មាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥០] មាត្រា ៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥១] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥២] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៧៣

ដែលភាគីបានដាក់ពាក្យបណ្ដឹងទៅតុលាការ[៥៣] ដោយអ្នកដាក់ពាក្យសុំ ដូចជា ពន្ធនៃការដាក់ពាក្យបណ្តឹង ឬ ពាក្យសុំផ្សេងៗ (ពាក្យសុំចាត់ចែងរក្សាការពារ, ពាក្យសុំចូលរួមអន្តរាគមន៍ជាដើម) ដែលទាក់ទងនឹងសកម្មភាពបណ្តឹង ពន្ធគណនាយកទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹងមកធ្វើជាមូលដ្ឋាន[៥៤] តម្លៃកម្មវត្ថុនៃបណ្តឹង ត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនោះ ហើយក្នុងករណីមានការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការទាមទារនោះ ត្រូវចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្តឹង[៥៥] ។ ចំពោះការទាមទារលើផលសំណងនៃការខូចខាតប្រាក់ធានាសងក្នុងករណីបំពានកិច្ចសន្យា ឬ សោហ៊ុយដែលជាកម្មវត្ថុបន្ទាប់បន្សំនៃបណ្តឹងមិនត្រូវបូកសរុបលើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងឡើយ[56] ។ ប៉ុន្តែក្នុងករណី មានការពិបាកក្នុងការគណនា តម្លៃកម្មវត្ថុនៃបណ្តឹង តុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិ ឬ ប្រសិនបើតម្លៃនោះ មិនអាចគណនាបានទេនោះត្រូវចាត់ទុកថា តម្លៃកម្មវត្ថុនៃបណ្តឹងមានចំនួន ប្រាំលានប្រាំសែនរៀល[៥៧]។

២) ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្តីតុលាការមួយប្រភេទ ដែលភាគីត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ចាំបាច់មួយសម្រាប់ការចំណាយរបស់តុលាការ ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង បញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងៗ មានសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅ ដែលចាំបាច់សម្រាប់ ចៅក្រម និង ក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាងការស្រាវជ្រាវអង្គហេតុ ឬ សកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តទៅនៅក្រៅតុលាការ[៥៨]។ ចំពោះប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធតុលាការត្រូវបង្គាប់ឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្តីបង់ជាមុន ប៉ុន្តែប្រសិនបើ សាមីខ្លួនពុំព្រមបង់ជាមុនទេ តុលាការអាចមិនធ្វើសកម្មភាពដែលចាំបាច់នោះ ឬ តុលាការអាចប្រមូលពីអ្នកដែលត្រូវទទួលនូវបន្ទុកលើការបង់ប្រាក់ប្រដាប់ក្តីទាំងមូល អាស្រ័យលើ

---

[៥៣] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៧៥

[៥៤] មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥៥] មាត្រា ៦០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥៦] មាត្រា ៦០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥៧] មាត្រា ៦០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៥៨] មាត្រា ៦២ កថាខណ្ឌទី ១ ចំណុច ក និង ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ដីកាសម្រេចរបស់តុលាការ[៥៩]។

៣)ប្រាក់ប្រដាប់ក្ដីភាគី គឺជាប្រាក់ប្រដាប់ក្ដីមួយប្រភេទ ដែលកំណត់ដោយតុលាការសម្រាប់ថ្លៃធ្វើលិខិតបណ្ដឹង លិខិតពាក្យសុំសោហ៊ុយធ្វើដំណើរ ឬ សោហ៊ុយផ្សេងៗ ដែលតុលាការទទួលស្គាល់ថា ជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្ដឹង[៦០]។

**កថាខណ្ឌទី ២ បន្ទុកនៃប្រាក់ប្រដាប់ក្ដី**

បន្ទុកនៃប្រាក់ប្រដាប់ក្ដី គឺជាការកំណត់នូវកាតព្វកិច្ចក្នុងការបង់ប្រាក់ប្រដាប់ក្ដីរបស់ភាគីនៃបណ្ដឹង ។ ជាទូទៅ ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ភាគីចាញ់ក្ដី ហើយក្នុងករណីចាញ់ក្ដីតែមួយភាគ តុលាការត្រូវសម្រេចបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយឆន្ទានុសិទ្ធិរបស់ខ្លួន[៦១]។ ប៉ុន្តែ តុលាការក៏អាចឱ្យភាគីឈ្នះក្ដីទទួលបន្ទុកប្រាក់ប្រដាប់ក្ដីទាំងអស់ ឬ មួយផ្នែកបានក្នុងករណីភាគីឈ្នះក្ដីបានប្រព្រឹត្តសកម្មភាពបណ្ដឹងណាមួយ ដែលមិនចាំបាច់ក្នុងការតទល់ ឬ ការពារខ្លួន ឬ បានធ្វើឱ្យនីតិវិធីបណ្ដឹងយឺតយ៉ាវ[៦២]។ ការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី ជាការសម្រេចរបស់តុលាការនៃការជំនុំជម្រះក្ដីនោះដោយឆន្ទានុសិទ្ធិ[៦៣]។ ប្រសិនបើ ពន្ធដាក់ពាក្យសុំត្រូវបានបង់ពន្ធលើស តុលាការនឹងសងពន្ធដែលបានបង់លើសនោះទៅវិញ។ ក្នុងករណីដែលភាគីយល់ព្រមសះជាមុនការទាញហេតុផលដោយផ្ទាល់មាត់ ករណីដកពាក្យបណ្ដឹង មុនបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង និងករណីដែលតុលាការលើកចោលបណ្ដឹងដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ចូលជាស្ថាពរ តុលាការត្រូវសងពាក់កណ្ដាលនៃពន្ធដែលបង់រួច[៦៤]។

**កថាខណ្ឌទី ៣ ប្រាតិភោគលើប្រាក់ប្រដាប់ក្ដី**

ប្រាតិភោគលើប្រាក់ប្រដាប់ក្ដី ជាសោហ៊ុយដែលត្រូវបង់ជាមុន ដើម្បីធានាដំណើរការនីតិវិធីក្នុងករណីដែលដើមចោទ គ្មានទីលំនៅឋាន ទីស្នាក់ការ កន្លែងអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា

[៥៩] មាត្រា ៦២ កថាខណ្ឌទី ៣ និងទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦០] មាត្រា ៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦១] មាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦២] មាត្រា ៦៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៣] មាត្រា ៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៤] មាត្រា ៦១ កថាខណ្ឌទី ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

តាមពាក្យសុំរបស់ចុងចម្លើយដោយដីកាសម្រេច។ ប្រសិនបើ មានមូលហេតុណាមួយចុងចម្លើយ អាចដាក់ពាក្យសុំទៅតុលាការឱ្យចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្ដីបាន លើកលែងតែ ចុងចម្លើយបានធ្វើការដោះសាក្នុងនីតិវិធីត្រៀម ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្ដីនៃបណ្ដឹងនៅក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ក្រោយពីបានដឹងថា មានមូលហេតុដែលអាចតម្រូវឱ្យដាក់ប្រាតិភោគ ចុងចម្លើយមិនអាចដាក់ពាក្យសុំបានទេ។ក្នុងករណី ចុងចម្លើយបានដាក់ពាក្យសុំឱ្យដាក់ប្រាតិភោគ តែដើមចោទមិនដាក់ ចុងចម្លើយអាចបដិសេធមិនព្រមតទល់នឹងបណ្ដឹងរហូតដល់ដើមចោទដាក់ប្រាតិភោគ[៦៥]។ ប៉ុន្តែប្រសិនបើដើមចោទមិនបានដាក់ប្រាតិភោគក្នុងអំឡុងពេលដែលត្រូវដាក់នោះទេ តុលាការអាចលើកបណ្ដឹងចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែប្រាតិភោគត្រូវបានដាក់មុនពេលចេញសាលក្រម[៦៦]។

### កថាខណ្ឌទី ៤ ការជួយសង្គ្រោះលើបណ្ដឹង

ការជួយសង្គ្រោះលើបណ្ដឹង គឺជាវិធានការអនុគ្រោះដែលតុលាការអនុញ្ញាតឱ្យពន្យាពេល ឬ អនុគ្រោះមិនចាំបាច់ឱ្យបង់ប្រាក់ប្រដាប់ក្ដី ដោយដីកាសម្រេចតាមពាក្យសុំរបស់បុគ្គលដែលអលទ្ធភាពបង់[៦៧]ដើម្បីចេញដីកាសម្រេចជួយសង្គ្រោះលើបណ្ដឹងបានត្រូវមានមូលហេតុដូចជា បុគ្គលដែលគ្មានលទ្ធភាពទ្រព្យធននឹងបង់ដែលចាំបាច់ដើម្បីរៀបចំ និងប្រព្រឹត្តទៅនៃនីតិវិធីបណ្ដឹង ឬ អាចមានការលំបាក់ខ្លាំង ក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់នេះ។ ការជួយសង្គ្រោះលើបណ្ដឹងនេះ អាចធ្វើបានបុគ្គលដែលគ្មានលទ្ធភាពបង់ ហើយមានភាពច្បាស់លាស់ថា អាចនឹងឈ្នះក្ដី[៦៨]។

## ផ្នែកទី ៥ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យានៅសាលាដំបូង

មុននឹងឈានចូលដល់នីតិវិធីចៅក្រមម្នាក់ និងក្រឡាបញ្ជីម្នាក់ជាអ្នកកត់ត្រា ចៅក្រមធ្វើការផ្សះផ្សាឱ្យគូភាគីទាំងពីរត្រូវរ៉ូវគ្នាវិញ ក្នុងគោលបំណងឱ្យគូភាគីមានការយោគយល់គ្នាទៅវិញទៅមក ដើម្បីឈានទៅរកការដកពាក្យបណ្ដឹងវិញ ។ ការផ្សះផ្សាឱ្យត្រូវរ៉ូវគ្នាវិញនេះ គឺចៅក្រមគាត់តែងប្រើរហូតដល់មុនពេលចេញសាលក្រម។ ផ្សះផ្សាជាដំណាក់កាលមួយដែលគូភាគីត្រូវបានចៅក្រម

[៦៥] មាត្រា ៦៧ កថាខណ្ឌទី ១ ទី ២ ទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៦] មាត្រា ៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៧] មាត្រា ៧០ កថាខណ្ឌទី ១ ចំណុច ក និង ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៨] មាត្រា ៦៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

សម្រុះសម្រួលឱ្យត្រូវគ្នាវិញ ក្នុងដំណាក់កាលនេះគូភាគីមិនចាំបាច់រកសាក្សី និង ភស្តុតាងអ្វីទេ។ ភារកិច្ចសំខាន់របស់ចៅក្រមពេលនេះគឺពន្យល់យ៉ាងណាឱ្យម្ចាស់បណ្ដឹងមានការអធ្យាស្រ័យយោគយល់ដល់កូនបំណុល ហើយពន្យល់កូនបំណុលឱ្យខិតខំប្រឹងប្រែងរកប្រាក់សងម្ចាស់បំណុល តាមកិច្ចសន្យា។ ក្នុងដំណាក់កាលនេះ ប្រសិនបើ គូភាគីសុខចិត្តតាមការសម្រុះសម្រួលរបស់ចៅក្រម គូភាគីអាចដកពាក្យបណ្ដឹងឈប់ប្ដឹងវិញបាន បើមិនសុខចិត្តតាមការសម្រុះសម្រួលរបស់ចៅក្រមទេ ត្រូវសុំតុលាការចាត់ការតាមនីតិវិធីតទៅទៀត ។ ជាពិសេសក្នុងដំណាក់កាលផ្សះផ្សា ចៅក្រមមិនទាន់ពិនិត្យដល់អង្គសេចក្ដីនៃរឿងវិវាទកិច្ចសន្យាទេ បានន័យថា ចៅក្រមមិនទាន់ពិនិត្យរកហេតុផល រកភស្តុតាងថា ភាគីនេះខុះនេះ ឬ ខុះនោះទេ[៦៩]។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (កថាខណ្ឌទី ១) ការទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី ២)។

**កថាខណ្ឌទី ១ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជានីតិវិធីត្រៀមរៀបចំសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដើម្បីសម្រួលដល់ការជម្រះក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងរៀបចំការអះអាងរបស់គូភាគី បំភ្លឺចំណុចវិវាទនៃរឿងក្ដី និងរៀបចំភស្តុតាងដែលមានការទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដី ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់[៧០]។ការរៀបចំការអះអាងរបស់គូភាគីគឺជាសេចក្ដីថ្លែងការណ៍មួយ ដែលរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬ មតិយោបល់តាមផ្លូវច្បាប់ ។ នៅក្នុងនីតិវិធីនៃបណ្ដឹងអង្គហេតុដែលមិនបានអះអាងដោយគូភាគី មិនអាចយកមកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមទេ[៧១] គូភាគីធ្វើការអះអាងនូវអង្គហេតុទាំងអស់ ដោយពុំគិតអំពីអង្គហេតុមាន ឬ គ្មានប្រយោជន៍ ដូចនេះ តុលាការត្រូវរៀបចំការអះអាងរបស់ភាគីដោយរៀបចំនូវចំណុចដែលភាគីមានទំនាស់ ឬ វិវាទនឹងគ្នា និង ឱ្យភាគីធ្វើការបំភ្លឺចំណុចវិវាទនោះដោយដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្ដឹង នឹងលុបចោលអង្គហេតុទាំងឡាយណាដែលគូភាគីធ្វើការអះអាងដូចគ្នា ដោយចាត់ទុកថាជា អង្គ

[៦៩] ហ៊ីង ធីឫទ្ធិ អត្ថាធិប្បាយច្បាប់ ភាគ ៣ ក្នុងរឿងរដ្ឋប្បវេណី សម្រាប់ប្រជារាស្ត្រសាមញ្ញ ភ្នំពេញ បោះពុម្ពលើកទី ២ ឆ្នាំ ២០០៧ ទំព័រ ១៨ ១៩

[៧០] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧១] មាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ហេតុដែលមិនមានវិវាទ។ ការរៀបចំចំណុចវិវាទដែលគូភាគីបានបំភ្លឺ ដើម្បីមានភាពងាយស្រួលក្នុងការចេញសាលក្រម។ តុលាការមិនអាចសម្រេចសេចក្តីអំពីភាពមាន ឬ មិនមានសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងនោះទេ ប្រសិនបើគ្មានការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តីនោះទោះបីជា ដើមចោទបានដាក់ពាក្យបណ្តឹងចំពោះចុងចម្លើយ ដោយអះអាងអំពីសិទ្ធិ ឬ កាតព្វកិច្ចដែលចុងចម្លើយត្រូវបំពេញក៏ដោយ ក៏មិនអាចសម្រេចបានថា សិទ្ធិទាមទារនោះមាន ឬ មិនមាននោះដែរ។ ការរៀបចំពិនិត្យភស្តុតាង ដែលពាក់ព័ន្ធនឹងរឿងក្តី ការអះអាងរបស់ភាគី ឬ ពាក់ព័ន្ធនឹងចំណុចវិវាទដែលត្រូវបំភ្លឺយកមកធ្វើជាមូលដ្ឋានវិនិច្ឆ័យនៅពេលទាញហេតុផលដោយផ្ទាល់មាត់។ ការរៀបចំភស្តុតាង មិនមែនជានីតិវិធីពិនិត្យភស្តុតាងនោះទេ ពោលគឺតុលាការគ្រាន់តែស្តាប់ការអះអាងរបស់ភាគី និង កំណត់ចំណុចវិវាទដែលភាគីនៃរឿងក្តីមិនស្របគ្នា ហើយរៀបចំភស្តុតាងដែលពាក់ព័ន្ធនឹងការអះអាងនោះប៉ុណ្ណោះ លើកលែងតែមានករណីចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី តុលាការអាចពិនិត្យភស្តុតាងឯកសារបាន ឬ ការចាត់ចែងថែរក្សាភស្តុតាង ដូចជា ការសាកសួរសាក្សីដែលមានជម្ងឺធ្ងន់ធ្ងរ ដែលអាចមានគ្រោះថ្នាក់ដល់ជីវិត ជាដើម[៧២] ។

### ក ឯកសារត្រៀម

ឯកសារត្រៀម គឺជាឯកសារដែលភាគីបានសរសេរត្រៀមមុនពេលចូលសវនាការអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលភាគីនឹងយកទៅអះអាងចំពោះមុខតុលាការ[៧៣]។ បន្ទាប់ពីភាគីបានទទួលដំណឹងនៃការប្តឹងទាមទាររបស់ភាគីដើមចោទក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយថ្ងៃតុលាការបានទទួលបណ្តឹងនោះមកចាត់ការ ភាគីត្រូវដាក់ឯកសារត្រៀមដោះសារ ឬ ឆ្លើយតប ឬ មធ្យោបាយតទល់ ចំពោះចំណុចទាមទារនានា ដោយផ្ទាល់មាត់នៅថ្ងៃត្រៀមទាញហេតុផល ឬ ករណីមិនអាចចូលរួមបាន ភាគីគ្រាន់តែធ្វើសេចក្តីថ្លែងការណ៍ស្តីពីការបដិសេធ ឬ ឆ្លើយតប ឬ មធ្យោបាយតទល់ចំពោះការទាមទារក្នុងបណ្តឹងរបស់អ្នកធ្វើបណ្តឹងក៏បាន។ ចំណែកឯកសារត្រៀមភាគីអ្នកធ្វើបណ្តឹងអាចដាក់បានក្រោយពីដាក់ពាក្យបណ្តឹងរួចហើយ។

### ខ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់

[៧២] មាត្រា ១៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧៣] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៩៥

ការទាញហេតុផលយ៉ាងឆាប់រហ័ស និង កោះហៅភាគី។ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ ថ្ងៃបន្ទាប់ពីពាក្យបណ្តឹងបានដាក់ លើកលែងតែមានមូលហេតុពិសេស កាលបរិច្ឆេទនេះ ហៅថាកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង[៧៤]។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន[៧៥] ។ ប៉ុន្តែ ប្រសិនបើតុលាការបានបញ្ជូនដីកាកោះ និងបានផ្តល់ឱកាសដល់ភាគីឱ្យបង្ហាញខ្លួន ហើយភាគីមិនបង្ហាញខ្លួន អាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។ រាល់កាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជី ធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[៧៦]។ នៅក្នុងកំណត់ហេតុនេះ ក្រឡាបញ្ជីត្រូវកត់ត្រានូវចំណុចនានា[៧៧] ហើយភាគី ឬ អ្នកដទៃ ដែលពាក់ព័ន្ធអាចប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រា នៅក្នុងកំណត់ហេតុនេះបាន[៧៨] ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សាជាដំបូងសិនលើកលែងតែក្នុងករណីដែលយល់ឃើញថា មិនសមរម្យ ដូចជា គូភាគីគ្មានបំណងនឹងសម្រុះសម្រួល ឬ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងមិនអនុញ្ញាតឱ្យចាត់ចែង[៧៩] ។ ក្នុងករណីដែលតុលាការធ្វើការផ្សះផ្សាមិនសម្រេច តុលាការត្រូវចាប់ផ្តើមនីតិវិធីត្រៀម ហើយតុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម[៨០]។ មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្តឹង[៨១] ប៉ុន្តែ ក្នុងករណីមានមូលហេតុពិសេស ភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួននៅពេលណាក៏បានមុនពេលបញ្ចប់ការវិនិច្ឆ័យលើបណ្តឹង។ ប្រសិនបើ ភាគីដាក់ទៅតុលាការយឺតយ៉ាវ មិនត្រូវនឹងពេលសមរម្យដោយចេតនា ឬ កំហុសធ្ងន់ធ្ងរ

---

[៧៤] មាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧៥] មាត្រា ១០៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧៦] មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧៧] មាត្រា ១១០ និងមាត្រា ១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧៨] មាត្រា ១១២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៧៩] មាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨០] មាត្រា ១០១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨១] មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

របស់ភាគី តុលាការអាចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួននោះដោយដីកាសម្រេចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ។ម្យ៉ាងវិញទៀត ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ហើយតុលាការទាមទារឱ្យបំភ្លឺតែភាគីមិនផ្តល់ការបំភ្លឺចាំបាច់ ឬមិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ឱ្យបំភ្លឺ តុលាការក៏អាចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួន នោះបានដែរ[៨២]។

**គ សកម្មភាពដែលអាចធ្វើបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាសកម្មភាពមួយចំនួនត្រូវបានកម្រិត ដូចជា ការពិនិត្យភស្តុតាងជាដើម ប៉ុន្តែ ដើម្បីរៀបចំការអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និង រៀបចំភស្តុតាងដែលត្រូវពិនិត្យនៅពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចធ្វើសកម្មភាពចាំបាច់មួយចំនួនបាន ដូចជា ចេញដីកាសម្រេចទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ដីកាសម្រេចទទួលយកភស្តុតាងដែលបានស្នើសុំឱ្យពិនិត្យ[៨៣] ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ[៨៤] និង ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ[៨៥] និង អនុញ្ញាតឱ្យធ្វើក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដូចជា ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង[៨៦] និង ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យចូលអន្តរាគមន៍ ក្នុងបណ្តឹងជាអាទិ៍[៨៧]។ ពិនិត្យភស្តុតាងជាឯកសារ ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ[៨៨]។

**ឃ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្តី និង ភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីអង្គហេតុ

[៨២] មាត្រា ៩៩ កថាខណ្ឌទី ១ ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨៣] មាត្រា ១២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨៤] មាត្រា ១៤៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨៥] មាត្រា ១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨៦] មាត្រា ៨៤ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨៧] មាត្រា ៩៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៨៨] មាត្រា ១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ដែលត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ[៥៩] ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីឱ្យចូលរួមតាមកាលកំណត់នោះ[៦០]។

**ខ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ក្រោយពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀតបានទេ នៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែ ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី ត្រូវបានអនុញ្ញាតក្នុងករណីដូចជា[៦១] មធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិដូចជា អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចជម្រះក្តី[៦២] អត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការដកហូតសមត្ថកិច្ចជម្រះក្តីជាដើម[៦៣]។ ការដាក់មធ្យោបាយថ្មីមិននាំឱ្យយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ដូចជា ការស្នើសុំឱ្យពិនិត្យភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ ឬ ភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា មិនអាចដាក់ភស្តុតាងនៅមុនបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរ។

**កថាខណ្ឌទី ២ ការទាញហេតុផលដោយផ្ទាល់មាត់**

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តី ដែលក្នុងនោះសកម្មភាពរបស់តុលាការ និង ភាគីចំពោះការជម្រះក្តីត្រូវធ្វើឡើង តាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្តាប់សេចក្តីថ្លែងការណ៍នោះ នៅសាលសវនាការបើកចំហរជាសាធារណៈនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន[៦៤]។ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើនូវកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ[៦៥] នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយ

[៥៩] មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦០] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦១] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦២] មាត្រា ១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៣] មាត្រា ២៧ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៤] មាត្រា ១១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៦៥] មាត្រា ១១៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចនានា[៩៦]។

**ក ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់**

នីតិវិធីនៃការជម្រះក្តីលើបណ្តឹង ត្រូវធ្វើឡើងដោយការទាញហេតុផលដោយផ្ទាល់មាត់[៩៧] ហៅថា នីតិវិធីចេញសាលក្រម។ ហេតុនេះ នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីមកចូលរួម[៩៨] ។ កាលបរច្ឆេទនេះ ច្បាប់មិនបានកំណត់អំឡុងពេលប៉ុន្មាននោះទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលឱ្យបានឆាប់រហ័ស ពីព្រោះការទទួលខុសត្រូវរបស់តុលាការ គឺប្រឹងប្រែងដើម្បីរ៉ាប់រងបណ្តឹងវិវាទកិច្ចសន្យាឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និង ឆាប់រហ័ស[៩៩] ។ ប៉ុន្តែ ចំពោះបណ្តឹងដែលមិនបានបំពេញលក្ខខណ្ឌ ដោយមានភាពផ្ទុយច្បាប់ តុលាការអាចចេញសាលក្រមលើកបណ្តឹងនោះចោលដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[១០០]។ ម្យ៉ាងវិញទៀត ចំពោះចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការអាចសម្រេចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនធ្វើបាន។ ទាក់ទងនឹងចំណុចដែលត្រូវសម្រេចដោយដីកាសម្រេច ក្នុងករណី តុលាការមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរភាគីបាន ដែលការសួរភាគី គឺជាការឱ្យភាគីមានឱកាសធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ[១០១]។

**ខ សកម្មភាពនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់**

កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ជាដំបូង ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ។ សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាសេចក្តីថ្លែងការណ៍សរុបអំពីសកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងនីតិវិធីត្រៀម ដូចនេះ តាមរយៈសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់

[៩៦] មាត្រា ១១៨ និងមាត្រា ១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៩៧] មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៩៨] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[៩៩] មាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១០០] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១០១] មាត្រា ១១៤ កថាខណ្ឌទី ១ និងទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ទាញហេតុផល ការអះអាងអង្គហេតុ ការដាក់ភស្តុតាង លទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ លទ្ធផលនៃការរៀបចំចំណុចវិវាទចាត់ទុកថា បានធ្វើនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនចាំបាច់ធ្វើសកម្មភាពទាំងនោះឡើងវិញទេ ។ នៅពេលធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលជាចំណុចវិវាទ[១០២] នៅពេលទាញហេតុផលដោយផ្ទាល់មាត់ គូភាគីអាចអះអាងបន្ថែមទៀតអំពីអង្គហេតុ និងដាក់ភស្តុតាងទៀតបាន ដោយតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងការអះអាងភាគីពីដំបូងហើយមិនធ្វើឱ្យមានភាពយឺតយ៉ាវដល់នីតិវិធីបណ្ដឹង[១០៣] ។ ក្នុងករណី មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីត្រូវបានដាក់ តុលាការត្រូវធ្វើការរៀបចំចំណុចវិវាទ និងភស្តុតាង នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ត្រឹមទំហំនៃមធ្យោបាយថ្មីនោះតែប៉ុណ្ណោះ។ ការពិនិត្យភស្តុតាងត្រូវធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[១០៤] ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលជាថ្មីម្ដងទៀតបាន[១០៥]។

### គ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីការពិនិត្យភស្តុតាងហើយ តុលាការត្រូវមានតួនាទីចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវចំពោះការទាមទាររបស់ដើមចោទ តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ចេញសាលក្រមចុងក្រោយ[១០៦]។ នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវប្រកាសអំពីការបញ្ចប់នីតិវិធីនោះ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗ ធ្វើសេចក្ដីថ្លែងការណ៍ចុងក្រោយបាននៅមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។ ទោះបីជាការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ក៏ដោយ បើយល់ឃើញថាចាំបាច់តុលាការអាចបើកឱ្យ

---

[១០២] មាត្រា ១១៦ កថាខណ្ឌទី ១ និងទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១០៣] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១០៤] មាត្រា ១២៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១០៥] មាត្រា ១១៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១០៦] មាត្រា ៨០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

មានការទាញហេតុផលជាថ្មីនៅមុនពេលចេញសាលក្រមចុងក្រោយបាន[107]។

## ផ្នែកទី ៦ ភស្តុតាង

ភស្តុតាង គឺជាតឹកតាងលាយលក្ខណ៍អក្សរ ឬ មិនមែនជាលាយលក្ខណ៍អក្សរ ហើយមានការពាក់ព័ន្ធនឹងចំណុចវិវាទរវាងគូភាគី ដែលធ្វើជាមូលដ្ឋានសម្រាប់ការវិនិច្ឆ័យសម្រេចសេចក្តីរបស់តុលាការ[108]។ គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង (កថាខណ្ឌទី ១) ការពិនិត្យភស្តុតាង (កថាខណ្ឌទី ២) ការថែរក្សាការពារភស្តុតាង (កថាខណ្ឌទី ៣)។

### កថាខណ្ឌទី ១ គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង

ជាគោលការណ៍ការសម្រេចសេចក្តីត្រូវផ្អែកលើភស្តុតាង ដើម្បីឱ្យតុលាការទទួលស្គាល់នូវអង្គហេតុភាគីត្រូវមានភស្តុតាងគ្រប់គ្រាន់ត្រឹមត្រូវច្បាស់លាស់។ ប៉ុន្តែ ក្រៅពីការទទួលស្គាល់នូវអង្គហេតុដោយភស្តុតាង ចៅក្រមអាចទទួលស្គាល់អង្គហេតុដោយពិចារណាទៅលើស្ថានភាពទាំងមូលដែលលើកឡើងដោយភាគីនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់មាន ដូចជា ភាពមិនស៊ីសង្វាក់គ្នាចំពោះការអះអាងរបស់ភាគី និងអ្នកតំណាងភាគី។ តុលាការទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន។ ការសារភាពក្នុងសវនាការមានអានុភាពចងភាគីផងដែរ ភាគីដែលបានសារភាពហើយ មិនអនុញ្ញាតឱ្យដកការសារភាព ឬ ធ្វើសេចក្តីថ្លែងការណ៍ផ្ទុយពីការសារភាពនោះឡើយ លើកលែងតែភាគីម្ខាងទៀតពុំតវ៉ា ការសារភាពនោះផ្ទុយនឹងការពិត មានការភាន់ច្រឡំ ការសារភាពបណ្តាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ[109]។ ផ្ទុយទៅវិញ បើភាគីមិនបង្ហាញច្បាស់លាស់នូវឆន្ទៈតវ៉ាអំពីអង្គហេតុ ដែលភាគីម្ខាងទៀតបានអះអាងនៅក្នុងនីតិវិធីត្រៀម ឬ ទាញហេតុផលដោយផ្ទាល់មាត់ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពចំពោះអង្គហេតុនោះ[110]។ ផ្ទុយទៅវិញ បើភាគីធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនដឹងអំពីអង្គហេតុ ដែលភាគីម្ខាងទៀត បានអះអាងភាគីនោះត្រូវសន្មតថា បានតវ៉ាចំពោះអង្គហេតុនោះ[111]។ ជាគោលការណ៍ អនុញ្ញាតឱ្យចៅក្រម

---

[107] មាត្រា ១៨០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[108] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៧៥

[109] មាត្រា ១២៣ កថាខណ្ឌទី ១ ទី ២ ទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[110] មាត្រា ៩៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ធ្វើការវាយតម្លៃ និង សម្រេចដោយសេរី ទៅលើលទ្ធផលនៃការពិនិត្យភស្តុតាង និង ទៅលើកាលៈទេសៈទាំងអស់ដែលលើកឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ក្នុងការទទួលស្គាល ឬមិនទទួលស្គាល់អង្គហេតុដែលជាមូលដ្ឋាននៃសាលក្រម[១១២]។ ការវាយតម្លៃដោយសេរី ជាការកំណត់ពីលទ្ធផលដែលបានមកពីការពិនិត្យភស្តុតាងមាន ឬ គ្មានប្រយោជន៍ចំពោះការទទួលស្គាល់អង្គហេតុណាមួយ ត្រូវស្ថិតក្រោមការវាយតម្លៃដោយសេរីរបស់ចៅក្រម។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍ជំនឿទុកចិត្តដោយសេរី មិនអនុញ្ញាតឱ្យចៅក្រមធ្វើតាមអំពើចិត្តរបស់ខ្លួន ក្នុងការទទួលស្គាល់អង្គហេតុនោះទេ ការទទួលស្គាល់អង្គហេតុ និង ការធ្វើជំនឿចិត្តត្រូវធ្វើឡើងតាមការវាយតម្លៃដោយត្រឹមត្រូវទៅលើភស្តុតាង និង ការសន្និដ្ឋាន។

**កថាខណ្ឌទី ២ ការត្រួតពិនិត្យភស្តុតាង**

ការត្រួតពិនិត្យភស្តុតាងត្រូវបានធ្វើឡើងតាមការស្នើសុំរបស់ភាគី ប្រសិនបើតុលាការមិនជឿជាក់ទៅលើការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីទាមទារឱ្យពិនិត្យ ឬ បើមានករណីចាំផ្សេងទៀត តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន[១១៣]។ ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវតែកំណត់ឱ្យជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង គប្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុ និង ភស្តុតាង ពីព្រោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុ និង ភស្តុតាងដែលតុលាការយល់ឃើញថា មិនចាំបាច់តុលាការមិនពិនិត្យភស្តុតាងដែលភាគីស្នើសុំឡើយ[១១៤]។ ការស្នើសុំឱ្យពិនិត្យភស្តុតាង អាចធ្វើនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃនីតិវិធីត្រៀម ឬមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[១១៥]។ ជាគោលការណ៍ តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំ លើកលែងតែភស្តុតាងដែលគ្មានទំនាក់ទំនងអង្គហេតុ ឬ ភស្តុតាងដែលតុលាការយល់ឃើញថា មិនចាំបាច់តុលាការមិនធ្វើការពិនិត្យភស្តុតាងទេ។

[១១១] មាត្រា ៩៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១២] មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១៣] មាត្រា ១២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១៤] មាត្រា ១២៥ កថាខណ្ឌទី ១ទី២ និងមាត្រា១២៦ វាក្យខណ្ឌទី ២នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១៥] មាត្រា ១២៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ម្យ៉ាងវិញទៀត ការស្នើសុំឱ្យពិនិត្យភស្តុតាងដែលយឿតយ៉ាវមិនសមស្របនឹងអំឡុងពេលសមរម្យ តុលាការត្រូវលើកចោលការស្នើសុំនោះ[១១៦]។

**ក ការសាកសួរសាក្សី**

ការសាកសួរសាក្សី គឺជាការសាកសួរសាក្សីណាដែលមានឈ្មោះនៅក្នុងពាក្យស្នើសុំរបស់ភាគី ដោយសួរសំនួរដែលមានផលប្រយោជន៍ដល់នីតិវិធី ហើយមានការពាក់ព័ន្ធនឹងរឿងវិវាទកិច្ចសន្យា។ ជនដែលមានឈ្មោះនៅក្នុងពាក្យស្នើសុំរបស់ភាគី ត្រូវមានករណីយកិច្ចធ្វើជាសាក្សីទាំងអស់ ហេតុនេះជនដែលតុលាការត្រូវបានកោះហៅជាសាក្សី មានករណីយកិច្ចត្រូវបង្ហាញខ្លួនចំពោះមុខតុលាការ ហើយមុននឹងឆ្លើយជាកសិណសាក្សី ជាគោលការណ៍ត្រូវធ្វើសម្បថ[១១៧]។ ផ្ទុយទៅវិញ បើសាក្សីមិនបង្ហាញខ្លួននៅចំពោះមុខតុលាការតាមដីកាកោះហៅ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចបង្គាប់ឱ្យនាំសាក្សីនោះ និង អាចពិន័យជាប្រាក់មិនលើសពីមួយលានរៀលដោយដីកាសម្រេច[១១៨]។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយច្បាប់លើកលែង ករណីយកិច្ចផ្ដល់ចម្លើយជាកសិណសាក្សី ចំពោះមន្ត្រីទូតដែលមានអភ័យឯកសិទ្ធិ ការសាកសួរសាក្សីជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ អំពីកិច្ចការសម្ងាត់ក្នុងមុខនាទីនោះ តុលាការត្រូវទទួលការយល់ព្រមពីសំណាក់ស្ថាប័នដែលគ្រប់គ្រងលើសាក្សីនោះ[១១៩]។ ការសាកសួរសាក្សី ត្រូវធ្វើឡើងនៅសាលសវនាការជាសាធារណៈ ប៉ុន្តែ ក្នុងករណី សាក្សីមិនអាចបង្ហាញខ្លួនចំពោះមុខតុលាការដោយសារជម្ងឺ ឬ ចាស់ជរា តុលាការអាចសាកសួរក្រៅតុលាការបាន[១២០]។

**ខ ការសាកសួរសាមីភាគី**

ការសាកសួរសាមីភាគី តុលាការអាចធ្វើការសាកសួរសាមីភាគីបានដោយឱ្យសាមីភាគីនោះស្បថ។ក្នុងករណីដែលធ្វើការសាកសួរសាមី បើភាគីណាមួយពុំចូលខ្លួន ឬបដិសេធនូវការធ្វើសម្បថ ឬ ផ្ដល់ចម្លើយ ដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្ដីអះអាងអំពី

[១១៦] មាត្រា ៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១៧] មាត្រា ១៣២ កថាខណ្ឌទី ១ និងមាត្រា ១៣៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១៨] មាត្រា ១៣២ កថាខណ្ឌទី ២ និងទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១១៩] មាត្រា ១៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២០] មាត្រា ១៣៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន[១២១]។ ផ្ទុយទៅវិញ បើភាគីណាមួយបានស្បថហើយ ប៉ុន្តែបើសម្បថនោះ ក្លែងបន្លំសេចក្តីសំអាង តុលាការអាចពិន័យជាប្រាក់មិនលើសពីពីរលានរៀលដោយដីកាសម្រេច[១២២]។ ភាពខុសគ្នារវាងការអះអាងរបស់ភាគី និង សេចក្តីថ្លែងការណ៍ជាភស្តុតាងរបស់ភាគី។ សេចក្តីថ្លែងការណ៍ក្នុងការសាកសួរសាមីភាគី គឺជាសកម្មភាពរៀបរាប់ដោយភាគីជូនចំពោះតុលាការនូវអ្វីៗ ដែលខ្លួនបានជួបប្រទះផ្ទាល់កាលពីមុន ឬ សកម្មភាពដើម្បីបញ្ជាក់ពីអង្គហេតុ ដែលភាគីនោះបានអះអាង ដូចនេះត្រូវចាត់ទុកជាភស្តុតាងរបស់សាក្សីដែរ។

**គ កោសលវិច័យ**

កោសលវិច័យ គឺជាការពិនិត្យភស្តុតាងមួយដើម្បីបង្គ្រប់ ចំពោះការដឹងរបស់ចៅក្រម ដែលតុលាការបង្គាប់ឱ្យតតិយជន ដែលមានចំណេះវិជ្ជា និង បទពិសោធន៍ពិសេសឱ្យធ្វើរបាយការណ៍អំពីវិធាន តាមបទពិសោធន៍ ដែលខ្លួនបានដឹងតតិយជននោះហៅថា អ្នកជំនាញខាងកោសលវិច័យ។ កោសលវិច័យ ជាប្រភេទមួយនៃការពិនិត្យភស្តុតាង ហេតុនេះជាគោលការណ៍ត្រូវធ្វើឡើងដោយការស្នើសុំរបស់ភាគី ដោយភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលសុំឱ្យធ្វើកោសលវិច័យ[១២៣]។ ប៉ុន្តែជននោះក៏អាចបដិសេធការធ្វើកោសលវិច័យបានដែរក្នុងករណី មានមូលហេតុ[១២៤]។ ប៉ុន្តែទោះបី អ្នកដែលតុលាការចាត់តាំងមិនព្រមធ្វើកោសលវិច័យ ដោយគ្មានមូលហេតុត្រឹមត្រូវក៏ដោយ ក៏ជននោះមិនត្រូវបានបង្ខំឱ្យធ្វើកោសលវិច័យ និងទទួលការពិន័យនោះទេ ពីព្រោះគេទទួលស្គាល់ថា ជនក្រៅពីតុលាការកំណត់ក៏មានជនផ្សេងទៀត ដែលមានចំណេះដឹង និង បទពិសោធន៍អាចធ្វើកោសលវិច័យជំនួសបាន[១២៥]។ ម្យ៉ាងវិញទៀត ក្នុងករណីមានហេតុរាំងដល់សច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញភាគីអាចប្តឹងផាត់ចោលអ្នកជំនាញកោសលវិច័យបាន[១២៦]។

[១២១] មាត្រា ១៤០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២២] មាត្រា ១៤០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២៣] មាត្រា ១៤៣ កថាខណ្ឌទី ១ និងទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២៤] មាត្រា ១៤៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២៥] មាត្រា ១៤៧ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២៦] មាត្រា ១៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

**ឃ ភស្តុតាងឯកសារ**

ភស្តុតាងជាឯកសារ ជាវត្ថុរូបិយ ដែលបង្កើតទំនាក់ទំនងសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីវិវាទ ជាលិខិតឯកជន ឬ លិខិតយថាភូត ឬ លិខិតជំនួញ ឬ សញ្ញាផ្សេងៗ ហៅថា ភស្តុតាងជាឯកសារ។ ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់ឯកសារ ដែលសាមីភាគីមាន ឬដាក់ពាក្យទៅតុលាការបង្គាប់ឱ្យផ្តល់ឯកសារដែលអ្នកដទៃកាន់កាប់ ឬ ដាក់ពាក្យសុំទៅតុលាការ ស្នើសុំឱ្យម្ចាស់ឯកសារផ្ញើឯកសារនោះ[១២៧]។ ក្នុងករណី តុលាការយល់ឃើញថា ពាក្យសុំដីកាបង្គាប់ឱ្យផ្តល់ឯកសារមានមូលហេតុត្រឹមត្រូវ តុលាការត្រូវបង្គាប់ដោយដីកាសម្រេច ឱ្យម្ចាស់ឯកសារផ្តល់ឯកសារ[១២៨]។ បុគ្គលដែលជាម្ចាស់ឯកសារ ពុំអាចបដិសេធផ្តល់ឯកសារបានឡើយ ប៉ុន្តែ ម្ចាស់ឯកសារអាចបដិសេធចំពោះការផ្តល់នេះបាន ប្រសិនបើឯកសារនោះមាន ដូចជា ឯកសារសរសេរឈ្មោះម្ចាស់ឯកសារ ឬ សហព័ទ្ធ ញាតិរបស់ខ្លួន ពាក់ព័ន្ធមន្ត្រីរាជការ និង ពាក់ព័ន្ធការសម្ងាត់វិជ្ជាជីវៈ[១២៩]។ ក្នុងករណីភាគី មិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារនោះទេ ឬ បានធ្វើឱ្យវិនាសបាត់បង់ ឬធ្វើឱ្យឯកសារនោះមិនអាចប្រើប្រាស់បាន ក្នុងគោលបំណងរារាំងដល់ការប្រើប្រាស់របស់ភាគីម្ខាងទៀត តុលាការត្រូវទទួលស្គាល់ថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀត ដែលពាក់ព័ន្ធនឹងខ្លឹមសារនោះជាការពិត[១៣០]។ ដោយឡែក បើតតិយជនដែលមានករណីកិច្ចផ្តល់ឯកសារ មិនគោរពតាមដីកាបង្គាប់ឱ្យផ្តល់ឯកសារ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពីពីរលានរៀល ដោយដីកាសម្រេច ហើយដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ពិន័យនេះហៅថា ពិន័យស៊ីវិល[១៣១]។ ការពិនិត្យភស្តុតាងឯកសារ គឺពិនិត្យលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ឯកសារនោះត្រូវបានបង្កើតឡើងដោយលើឆន្ទៈរបស់ដែលធ្វើឯកសារនោះក្នុងនាមខ្លួន ភាគីដែលបានស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារត្រូវបញ្ជាក់ថា ឯកសារនោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ប៉ុន្តែបើ ឯកសារនោះមានចុះហត្ថលេខារបស់សាមីខ្លួន ឬ អ្នកតំណាងភាពត្រឹមត្រូវក្នុងការបង្កើតឯកសារនោះត្រូវបានសន្មត[១៣២]។ ឯកសារ

[១២៧] មាត្រា ១៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២៨] មាត្រា ១៥២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១២៩] មាត្រា ១៥០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣០] មាត្រា ១៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣១] មាត្រា ១៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

សាធារណៈ បើទទួលស្គាល់តាមទម្រង់ និង ខ្លឹមសារនៃឯកសារនោះថា ឯកសារនោះត្រូវធ្វើឡើងដោយមន្ត្រីរាជការក្នុងមុខនាទី ភាពត្រឹមត្រូវនៃការបង្កើតឯកសារត្រូវបានសន្មត អ្នកស្នើសុំឱ្យពិនិត្យឯកសារមិនចាំបាច់បញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារទេ[១៣៣]។ ក្រៅពីភស្តុតាងជាឯកសារ មានវត្ថុដែលទុកដូចជាឯកសារមាន ប្លង់ រូបថត ខ្សែអាត់ ខ្សែវីដេអូ និង វត្ថុដទៃទៀត ដែលបង្កើតឡើងសម្រាប់ផ្តល់ព័ត៌មាន អនុវត្តដូចគ្នាផងដែរនឹងការពិនិត្យភស្តុតាងជាឯកសារ[១៣៤]។ ចំពោះភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងជាខ្សែអាត់ជាដើម ត្រូវដាក់ឯកសារដែលបានកត់ចម្លងអត្ថន័យចេញពីវត្ថុខ្សែអាត់នោះ ឬ ឯកសារដែលពន្យល់អំពីអត្ថន័យនៃវត្ថុនោះ បើមានសំណូមពរពីតុលាការ ឬ ភាគីម្ខាងទៀត[១៣៥]។

### ខ ការត្រួតពិនិត្យ

ការត្រួតពិនិត្យ គឺជាការត្រួតពិនិត្យទៅលើភិនភាគ ឬ បាតុភូតនៃវត្ថុផ្ទាល់ដោយចៅក្រម ហើយកម្មវត្ថុនៃការត្រួតពិនិត្យ គឺមនុស្ស និងវត្ថុ ហៅថា កម្មវត្ថុដែលត្រូវត្រួតពិនិត្យ។ ការត្រួតពិនិត្យធ្វើឡើង ដោយការស្នើសុំ និងចង្អុលបង្ហាញនូវវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ[១៣៦]។

### កថាខណ្ឌទី ៣ ការថែរក្សាការពារភស្តុតាង

ការពិនិត្យភស្តុតាង ជាគោលការណ៍ ត្រូវធ្វើឡើងក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែ ប្រសិនបើចាំដល់ដំណាក់កាលនោះនឹងមិនអាច ឬ ពិបាកនឹងពិនិត្យភស្តុតាងបាន ដូចជា ជនដែលនឹងក្លាយជាសាក្សីទទួលមរណភាព ឬ គ្រោះថ្នាក់ ឬ ចេញទៅបរទេស ឬ ករណីលួចកែឯកសារ ផ្លាស់ប្តូរនូវស្ថានភាពដែលទីកន្លែងត្រូវត្រួតពិនិត្យជាដើម ក្នុងករណីមានស្ថានភាពដូចរៀបរាប់ខាងលើខាងលើ តុលាការអាចពិនិត្យភស្តុតាងជាមុនបាន តាមពាក្យសុំ[១៣៧]ដោយនីតិវិធីមួយហៅថា នីតិវិធីរក្សាការពារភស្តុតាង។

---

[១៣២] មាត្រា ១៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣៣] មាត្រា ១៥៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣៤] មាត្រា ១៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣៥] មាត្រា ១៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣៦] មាត្រា ១៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣៧] មាត្រា ១៦៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

នីតិវិធីថែរក្សាការពារភស្តុតាង អាចចាប់ផ្តើមមុនពេលដាក់ពាក្យបណ្តឹងក៏បានក្រោយពេលដាក់ពាក្យបណ្តឹងក៏បាន តែមុនដំណាក់កាលនៃការពិនិត្យភស្តុតាង។ នីតិវិធីរក្សាការពារភស្តុតាង ជាទូទៅ ត្រូវចាប់ផ្តើមដោយពាក្យសុំរបស់ភាគី ប៉ុន្តែក្រោយពេលមានពាក្យបណ្តឹង ប្រសិនបើយល់ឃើញថា ចាំបាច់តុលាការអាចចាប់ផ្តើមនីតិវិធីរក្សាការពារភស្តុតាងដោយឆន្ទានុសិទ្ធិ[១៣៨]។ ពាក្យសុំរក្សាការពារភស្តុតាងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង សរសេរនូវចំណុចចាំបាច់នានា[១៣៩] ហើយពាក្យសុំនេះ ត្រូវដាក់ទៅសាលាដំបូងមានសមត្ថកិច្ចនៅទីសំណាក់របស់បុគ្គលដែលត្រូវទទួល ការសាកសួរ ឬបុគ្គលដែលជាម្ចាស់ឯកសារ ឬទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ប្រសិនបើការរក្សាការពារភស្តុតាង ធ្វើមុនពេលដាក់ពាក្យបណ្តឹង។ផ្ទុយមកវិញ បើពាក្យសុំថែរក្សាការពារភស្តុតាង ធ្វើក្រោយដាក់ពាក្យបណ្តឹងពាក្យសុំនោះ ត្រូវដាក់ទៅតុលាការនៃលំដាប់ថ្នាក់ ដែលភស្តុតាងនោះត្រូវប្រើប្រាស់ ប៉ុន្តែក្នុងករណីមានស្ថានភាពបន្ទាន់ ទោះជានៅក្រោយពេលដាក់ពាក្យបណ្តឹងក៏ដោយក៏ពាក្យសុំថែរក្សាការពារភស្តុតាង អាចធ្វើនៅសាលាដំបូងបាន[១៤០]។ ជាធម្មតា ភាគីដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ត្រូវកំណត់បុគ្គលដែលជាភាគីម្ខាងទៀត ប៉ុន្តែដោយសារការថែរក្សាការពារភស្តុតាង អាចចាប់ផ្តើមមុនការដាក់ពាក្យបណ្តឹង ហេតុនេះ បើមានករណីដែលមិនដឹងថាអ្នកណាជាភាគីម្ខាងទៀត នោះតុលាការអាចជ្រើសតាំងអ្នកតំណាងពិសេស សម្រាប់ជនដែលក្លាយជាភាគីម្ខាងទៀតបាន[១៤១]។ លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានរក្សាការពារមានអានុភាពជាភស្តុតាងនៅក្នុងបណ្តឹងអង្គសេចក្តី[១៤២]។ ប៉ុន្តែ ចំពោះការសាកសួរសាក្សី ទោះបីជាបានធ្វើនៅក្នុងនីតិវិធីថែរក្សាការពារភស្តុតាងក៏ដោយ តុលាការត្រូវសាកសួរសាក្សីនោះ នៅពេលទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើភាគីទាមទារឱ្យសាកសួរសាជាថ្មី[១៤៣]។

[១៣៨] មាត្រា ១៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៣៩] មាត្រា ១៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤០] មាត្រា ១៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤១] មាត្រា ១៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤២] មាត្រា ១៦៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤៣] មាត្រា ១៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

## ផ្នែកទី ៧ បណ្តឹងទាស់

បណ្តឹងទាស់ (កថាខណ្ឌទី ១) របៀបធ្វើបណ្តឹងទាស់(កថាខណ្ឌទី ២)និងអានុភាពនៃបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់ (កថាខណ្ឌទី ៣)។

### កថាខណ្ឌទី ១ បណ្តឹងទាស់

បណ្តឹងទាស់ ជាផ្លូវតវ៉ាដែលបើកសិទ្ធិឱ្យភាគីដែលមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ប្តឹងទៅតុលាការដែលបានចេញសាលក្រមឱ្យលើកយករឿងនេះមកចាត់ការឡើងវិញតាមនីតិវិធីត្រឹមពេលវត្តមានកើតឡើង បន្ទាប់ពីបានទទួលសាលក្រមកំបាំងមុខ ដោយមានមូលហេតុមិនអាចព្យាករណ៍បាន ឬ មានមូលហេតុមិនអាចជៀសវាងបាន។ បណ្តឹងទាស់ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២(ពីរ)សប្តាហ៍ ដោយគិតចាប់ពីរថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ អំឡុងពេលនេះមិនអាចពន្យាបានទេ ។ ប្រសិនបើ សាលក្រមកំបាំងមុខនោះ ត្រូវបានបញ្ជូនតាមរយៈការបិទប្រកាសជាសាធារណៈ ឬ តាមរយៈការបញ្ជូនទៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចឱ្យភាគីនោះប្តឹងទាស់បាន នៅក្នុងសាលក្រមកំបាំងមុខនោះ[១៤៤]។

### កថាខណ្ឌទី ២ របៀបធ្វើបណ្តឹងទាស់

របៀបប្តឹងទាស់ គឺជារបៀបមួយប្រាប់អំពីនីតិវិធីនៃការធ្វើប្តឹងទាស់ ក្រោយពីគូភាគីណាមួយមិនបានចូលមកពេលសវនាការតុលាការចេញសាលក្រមកំបាំងមុខ។ ការប្តឹងទាស់ត្រូវបានធ្វើឡើងដោយការដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខនោះ ។ នៅក្នុងពាក្យបណ្តឹងទាស់ ត្រូវសរសេរចំណុចដូចខាងក្រោម៖

១) ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

២) សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់។

៣) បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលបានកំណត់ក្នុងចំណុចទី ២ខាងលើនេះ។

៤) មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា[១៤៥]។

#### ក ការពិនិត្យ និង ការបញ្ជូនពាក្យបណ្តឹងទាស់

ការពិនិត្យពាក្យបណ្តឹងទាស់ គឺជាការពិនិត្យរកលក្ខណៈស្របច្បាប់ត្រឹមត្រូវទៅតាមរបៀប

[១៤៤] មាត្រា ២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤៥] មាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ប្តឹងទាស់ ហើយតុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ។ ប្រសិនបើភាគីដែលប្តឹងទាស់មិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យបណ្តឹងទាស់នោះចោលដោយដីកាសម្រេច ហើយដីកាសម្រេចនោះអាចប្តឹងជំទាស់បាន។ ចំណែកឯការបញ្ជូនពាក្យបណ្តឹងទាស់ ប្រសិនបើពាក្យបណ្តឹងទាស់គ្មានចំណុចណាមួយខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្តឹងទាស់នោះ និង កោះហៅគូភាគី[១៤៦]។

**ខ ការវិនិច្ឆ័យ និង ការសម្រេចសេចក្តីលើបណ្តឹងទាស់**

តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃពាក្យបណ្តឹងទាស់តាមទម្រង់ និងអំឡុងពេលដែលកំណត់ដោយច្បាប់ និង អំពីភាពត្រឹមត្រូវនៃមូលហេតុបណ្តឹងទាស់។ តុលាការត្រូវលើកចោលនូវបណ្តឹងទាស់ ដោយដីកាសម្រេច ប្រសិនបើយល់ឃើញថា ពាក្យបណ្តឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ តែបើយល់ឃើញថា ពាក្យបណ្តឹងទាស់នោះ គ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវច្រានចោលបណ្តឹងទាស់នោះដោយដីកាសម្រេច[១៤៧]។

**កថាខណ្ឌទី ៣ អានុភាពនៃបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់**

អានុភាពនៃបណ្តឹងទាស់ ជាពាក្យបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់ដោយតុលាការ ហើយនីតិវិធីនៃបណ្តឹងនោះត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតឡើង។ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្តើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាថ្មីឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យគូភាគី[១៤៨]។

**ក សាលក្រមថ្មី**

សាលក្រមថ្មី គឺជាសាលក្រមដែលតុលាការត្រូវចេញដោយផ្អែកលើការជំនុំជម្រះសារជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ មានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះចាត់ទុកថាជាសាលក្រមបានការ។ ប្រសិនបើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្ត

---

[១៤៦] មាត្រា ២០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤៧] មាត្រា ២០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៤៨] មាត្រា ២០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

នីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះ អាចមានដូចជា ការលុបចោលទាំងអស់ ឬ លុបចោលតែមួយភាគ[១៤៩]។

**ខ សោហ៊ុយដែលកើតឡើងដោយសារអវត្តមានភាគី**

សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន ជាសោហ៊ុយសម្រាប់ការបញ្ជូនពាក្យបណ្តឹងទាស់ សោហ៊ុយស្រាវជ្រាវមូលហេតុនៃបណ្តឹងទាស់ ជាដើម ត្រូវជាបន្ទុករបស់ភាគីអវត្តមាន ដោយហេតុថា ភាគីម្ខាងទៀតមិនមានកំហុសនាំឱ្យមានចំណាយបន្ថែមនោះឡើយ លើកលែងតែករណីដែលសោហ៊ុយនោះបានកើតឡើង ដោយសារសកម្មភាពមិនត្រឹមត្រូវរបស់ភាគីម្ខាងទៀត[១៥០]។

**គ សាលក្រមកំបាំងមុខលើកទីពីរ**

បើភាគីដែលបានប្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្តើមអនុវត្តនីតិវិធីថ្មីទេ តុលាការត្រូវច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខម្តងទៀត លើកលែងតែមានមូលហេតុដូចជា ភាគីមិនបានទទួលការកោះហៅស្របច្បាប់ ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន បណ្តឹងមិនស្របច្បាប់ សេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ និង តុលាការបានពន្យារកាលបរិច្ឆេទ ហើយមិនបានធ្វើការកោះហៅភាគី តាមកាលបរិច្ឆេទថ្មីនោះ ប្រសិនបើមានមូលហេតុដូចរៀបរាប់មកនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានទេ។ ប៉ុន្តែ ប្រសិនបើភាគីនោះបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូង ហើយអវត្តមាននៅកាលបរិច្ឆេទក្រោយទៀត តុលាការមិនអាចច្រានចោលបណ្តឹងទាស់ដោយសាលក្រមកំបាំងមុខម្តងទៀតបានទេ។ ក្នុងករណីនេះតុលាការចេញសាលក្រមកំបាំងមុខធម្មតាវិញ ប៉ុន្តែ ប្រសិនបើភាគីដែលបានប្តឹងទាស់មិនបានបង្ហាញខ្លួននៅក្នុងនីតិវិធីដំបូងដោយឥតមូលហេតុដូចខាងលើនេះទេ តុលាការនឹងច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខម្តងទៀត ភាគីមិនអាចប្តឹងទាស់បានទៀតទេ[១៥១]។

## ផ្នែកទី ៨ បណ្តឹងតប

បណ្តឹងតប (កថាខណ្ឌទី ១) លក្ខខណ្ឌនៃបណ្តឹងតប (កថាខណ្ឌទី ២) និង ការចាត់ចែងបណ្តឹងតប (កថាខណ្ឌទី ៣)។

---

[១៤៩] មាត្រា ២០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥០] មាត្រា ២១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥១] មាត្រា ២១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

**កថាខណ្ឌទី ១ បណ្តឹងតប**

បណ្តឹងតប ជាបណ្តឹងដែលធ្វើឡើងដោយចុងចម្លើយចំពោះដើមចោទ។ ជាទូទៅចុងចម្លើយអាចប្តឹងតបដើមចោទបាន លុះត្រាណាតែបណ្តឹងដែលធ្វើឡើងដោយដើមចោទនោះ កំពុងត្រូវបានចាត់ការ ឬ រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវមានកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារ ដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬជាមធ្យោបាយការពារខ្លួន សម្រាប់បណ្តឹងដើម[១៥២]។

**កថាខណ្ឌទី ២ លក្ខខណ្ឌនៃបណ្តឹងតប**

បណ្តឹងតបត្រូវវិនិច្ឆ័យ និង ចេញសាលក្រមដោយនីតិវិធីប្រភេទបណ្តឹងដូចគ្នា[១៥៣]។ មិនមានបញ្ញត្តិពិសេសណាមួយហាមឃាត់ចំពោះការធ្វើបណ្តឹងតបនោះទេ លើលែងតែបណ្តឹងតបនោះខុសលក្ខខណ្ឌនៃបណ្តឹងតប[១៥៤]។ ការទាមទារចំពោះបណ្តឹងតប ត្រូវមានទំនាក់ទំនង និង ការទាមទារនៃបណ្តឹងដើម ឬ មានទំនាក់ទំនងនឹងមធ្យោបាយការពារខ្លួនចំពោះការទាមទារនៃបណ្តឹងដើម[១៥៥]។ការទាមទារចំពោះបណ្តឹងតបត្រូវមានទំនាក់ទំនងនឹងបណ្តឹងដើម មានន័យថា ការទាមទារនៃបណ្តឹងដើម និង ការទាមទារនៃបណ្តឹងតប ជាការទាមទារដែលពាក់ព័ន្ធនឹងកម្មវត្ថុដូចគ្នា ឬ កើតឡើងពីអង្គហេតុដូចគ្នា។ នីតិវិធីនៃបណ្តឹងមិននាំឱ្យមានភាពយឺតយ៉ាវខ្លាំងទេ ដោយសារការដាក់បណ្តឹងតបនេះ ស្ថិតនៅក្រោមសមត្ថកិច្ចតុលាការដែលបានជំនុំជម្រះលើកទីមួយ[១៥៦]។

**កថាខណ្ឌទី ៣ ការចាត់ចែងបណ្តឹងតប**

ការចាត់ចែងបណ្តឹងតប គឺជាការចាត់ចែងនូវបណ្តឹងដោយតុលាការមានសមត្ថកិច្ចផ្តាច់មុខ ហើយតុលាការនោះត្រូវផ្ទេរបណ្តឹងតបទៅតុលាការបណ្តឹងដើម ឬ តុលាការដែលបានទទួលនូវការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ។ ប្រសិនបើលក្ខខណ្ឌនៃបណ្តឹងតបត្រឹមត្រូវ តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រមអំពីបណ្តឹងដើម និងបណ្តឹងតបដោយនីតិវិធីដូចគ្នានឹងបណ្តឹង

[១៥២] ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រ ៧០

[១៥៣] មាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥៤] មាត្រា ២២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥៥] មាត្រា ៨៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥៦] មាត្រា ៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ដើម។ ក្នុងករណីដែលបណ្តឹងតបមិនស្របនឹងលក្ខខណ្ឌនៃបណ្តឹងតប តុលាការត្រូវបំបែករឿងចែករឿងក្តីនោះ ហើយចាត់ចែងបណ្តឹងតបជាបណ្តឹងឯករាជ្យមួយ និង ត្រូវធ្វើការវិនិច្ឆ័យផ្សេងគ្នា [១៥៧]។ ប៉ុន្តែ បណ្តឹងតប មានទំនាក់ទំនងជាមួយបណ្តឹងដើម នាំឱ្យយើងអាចបកស្រាយថា ប្រសិនបើកម្មវត្ថុនៃបណ្តឹងតបដូចគ្នានឹងបណ្តឹងដើម បណ្តឹងតបនោះមិនត្រូវការបង់ពន្ធឡើយ ផ្ទុយទៅវិញ បើកម្មវត្ថុនៃបណ្តឹងតបខុសគ្នានឹងបណ្តឹងដើម បណ្តឹងតបនោះត្រូវការបង់ពន្ធ[១៥៨]។

## ផ្នែកទី ៩ ការបញ្ចប់វិវាទកិច្ចសន្យានៅសាលាដំបូង

វិវាទត្រូវបញ្ចប់ដោយតុលាការនៅសាលាដំបូងមាន ការបញ្ចប់វិវាទកិច្ចសន្យាដោយសាលក្រមចុងក្រោយ (កថាខណ្ឌទី ១)ការបញ្ចប់វិវាទកិច្ចសន្យាដោយមិនចេញសាលក្រម(កថាខណ្ឌទី ២) ការបញ្ចប់វិវាទកិច្ចសន្យាដោយស្វ័យប្រវត្តិ (កថាខណ្ឌទី ៣)។

### កថាខណ្ឌទី ១ ការបញ្ចប់វិវាទកិច្ចសន្យាដោយសាលក្រមចុងក្រោយ

វិវាទកិច្ចសន្យា ត្រូវបានបញ្ចប់ដោយសាលក្រមរបស់តុលាការដែលជាការឆ្លើយតប ចំពោះការទាមទាររបស់ដើមចោទនោះ។នៅពេលដែលការវិនិច្ឆ័យចប់ជាមួយនឹងការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ដោយកំណត់កាលបរិច្ឆេទនៃការប្រកាសសាលក្រម និងប្រកាសសាលក្រម[១៥៩]។នៅពេលដែលប្រកាសសាលក្រមនោះចូលជាស្ថាពរ គោលដៅនៃបណ្តឹងត្រូវបានសម្រេច ករណីនេះ ហៅថា ការបញ្ចប់វិវាទដោយសាលក្រម ឬ ការបញ្ចប់វិវាទដោយសកម្មភាពរបស់តុលាការ ។ សាលក្រមដែលមានអានុភាពបញ្ចប់វិវាទចាំបាច់ត្រូវតែជាសាលក្រមបញ្ចប់រឿងក្តីមួយភាគ ឬ ទាំងមូលហើយសាលក្រមបែបនេះហៅថា សាលក្រមចុងក្រោយ ដូចនេះ សាលក្រមរបៀបពុំមានអានុភាពបញ្ចប់វិវាទនោះទេ ពីព្រោះសាលក្រមរបៀបនេះ មានគោលបំណងរៀបចំ និង សម្រួលធ្វើឱ្យការវិនិច្ឆ័យមានសណ្តាប់ធ្នាប់ប៉ុណ្ណោះ មុនចេញសាលក្រមចុងក្រោយ។ សាលក្រមចុងក្រោយត្រូវបានបែងចែកជា ៣ ប្រភេទគឺ៖

១) សាលក្រមលើកបណ្តឹងចោល ដោយមិនធ្វើការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ ការទាមទារមិនត្រឹមត្រូវ ដោយខ្វះលក្ខខណ្ឌនៃបណ្តឹង សាលក្រមប្រភេទនេះ ហៅថា សាលក្រមនីតិវិធី។

---

[១៥៧] មាត្រា ៩៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥៨] មាត្រា ៦០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៥៩] មាត្រា ១៨០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

២) សាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ ជាបណ្ដឹងដែលមានលក្ខខណ្ឌគ្រប់គ្រាន់តាមផ្លូវច្បាប់ សាលក្រមប្រភេទនេះ ហៅថា សាលក្រមទទួលស្គាល់ការទាមទារ។

៣) សាលក្រមមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ សាលក្រមប្រភេទនេះ ហៅថា សាលក្រមច្រានចោលការទាមទារ។សាលក្រមទទួលស្គាល់ការទាមទារ និងសាលក្រមច្រានចោលការទាមទារ គេហៅជារួមថា សាលក្រមលើអង្គហេតុ ពីព្រោះសាលក្រមទាំងពីរនេះ គឺជាសាលក្រមបង្ហាញអំពីការសម្រេចសេចក្ដីរបស់តុលាការស្ដីពីភាពត្រឹមត្រូវនៃការទាមទារដែលជាកម្មវត្ថុដើមនៃបណ្ដឹង។ សាលក្រមចុងក្រោយ និង មានអានុភាពដោយការប្រកាស ហើយអានុភាពផ្សេងៗ ទៀតនឹងកើតមានឡើង ដូចជា អត្តពន្ធភាពនៃសាលក្រម អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ និង អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុហៅថា អានុភាពរួម ។ ក្រៅពីអានុភាពនេះ សាលក្រមមានអានុភាពអនុវត្តផងដែរ ប៉ុន្តែអានុភាពអនុវត្តមានចំពោះតែសាលក្រមបង្គាប់ឱ្យផ្ដល់តាវកាលិកតែប៉ុណ្ណោះដូចនេះ សាលក្រមបង្កើត ផ្លាស់ប្ដូរ រំលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត និងសាលក្រមបញ្ជាក់ពុំមានអានុភាពអនុវត្តទេ ហៅថា អានុភាពដោយឡែក។

**កថាខណ្ឌទី ២ ការបញ្ចប់វិវាទកិច្ចសន្យាដោយមិនចេញសាលក្រម**

ការដកពាក្យបណ្ដឹង គឺជាសកម្មភាពបណ្ដឹងរបស់ដើមចោទ ដែលសុំដកមួយភាគ ឬ ទាំងស្រុងនូវពាក្យសុំទាមទារឱ្យចេញសាលក្រមតាមរយៈបណ្ដឹង ហើយការដកពាក្យបណ្ដឹងត្រូវធ្វើឡើងនៅក្នុងនីតិវិធីនៃបណ្ដឹង។ ដើមចោទ អាចដកពាក្យបណ្ដឹងពេលណាក៏បាន រហូតដល់ពេលសាលក្រមចុងក្រោយចូលជាស្ថាពរ ទោះបីសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាសហើយក៏ដោយក៏ដើមចោទ អាចដកពាក្យបណ្ដឹងបានមុនពេលសាលក្រមនោះចូលជាស្ថាពរ[១៦០] ។ ប៉ុន្តែ ចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្ដី ឬ បានធ្វើសេចក្ដីថ្លែងការណ៍អំពីអង្គសេចក្ដី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ ការដកពាក្យបណ្ដឹងមានអានុភាពលុះត្រាតែមានការយល់ព្រមពីចុងចម្លើយ[១៦១]។ ការយល់ព្រមនេះ ទោះបីជាចុងចម្លើយមិនយល់ព្រមដោយជាក់ស្ដែងក៏ដោយក៏ចាត់ទុកថា ចុងចម្លើយបានយល់ព្រម ក្នុងករណីដើមចោទដាក់លិខិតដកពាក្យបណ្ដឹងទៅតុលាការ ហើយក្រឡាបញ្ជីធ្វើការបញ្ជូនលិខិតនោះទៅចុងចម្លើយតែចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល ២សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលលិខិត

[១៦០] មាត្រា ២១៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦១] មាត្រា ២១៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

នោះ ឬ បើដើមចោទ បានដកពាក្យបណ្ដឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទត្រៀម ឬ កាលបរិច្ឆេទទាញហេតុផល ឬ កាលបរិច្ឆេទនៃការផ្សះផ្សាដែលដើមចោទមានវត្តមាន ប៉ុន្តែ ចុងចម្លើយមិនតវ៉ាក្នុងអំឡុងពេល ២សប្ដាហ៍ គិតពីកាលបរិច្ឆេទនោះ[១៦២]។ ជាគោលការណ៍ ការដកពាក្យបណ្ដឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ក្នុងករណីនេះ តុលាការត្រូវបញ្ជូនលិខិតដកពាក្យបណ្ដឹងទៅចុងចម្លើយ[១៦៣]។ ប៉ុន្តែនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាអាទិ៍ ការដកពាក្យបណ្ដឹងអាចធ្វើដោយផ្ទាល់មាត់បានដោយក្រឡាបញ្ជី ត្រូវចុះអំពីការដកពាក្យបណ្ដឹងនោះនៅក្នុងកំណត់ហេតុនៃកាលបរិច្ឆេទនីមួយៗ ដើម្បីកុំឱ្យមានវិវាទនៅពេលក្រោយ ហើយតុលាការត្រូវបញ្ជូនឯកសារចម្លងនៃកំណត់ហេតុនោះទៅចុងចម្លើយ ប៉ុន្តែបើចុងចម្លើយ បានចូលរួមក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាដើម ការបញ្ជូនមិនត្រូវធ្វើឡើងឡើយ[១៦៤]។ នៅពេលដែលមានការដកពាក្យបណ្ដឹង ផ្នែកដែលត្រូវបានដក ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូងដូចនេះ សកម្មភាពរបស់តុលាការ និង ភាគីបានធ្វើរហូតដល់ពេលដកពាក្យបណ្ដឹងនឹងបាត់បង់អានុភាពទាំងអស់[១៦៥]។ ក្នុងករណីដែលដកពាក្យបណ្ដឹងក្រោយពេលចេញសាលក្រមចុងក្រោយ មិនអាចដាក់ពាក្យបណ្ដឹងដូចគ្នាទៀតបានទេ ។ បញ្ញត្តិនេះ មានគោលគំនិតកុំឱ្យដើមចោទដែលលុបអានុភាពនៃសាលក្រមសម្រេចអង្គសេចក្ដីដោយដកពាក្យបណ្ដឹង អាចដាក់ពាក្យបណ្ដឹងម្ដងទៀត និង នាំឱ្យតុលាការនិងចុងចម្លើយចូលក្នុងនីតិវិធីដដែលៗ បាន ។ ប៉ុន្តែ ប្រសិនបើមានសេចក្ដីត្រូវការចាំបាច់ក្នុងការដាក់ពាក្យបណ្ដឹងថ្មីកើតឡើង ត្រូវអនុញ្ញាតឱ្យដាក់ពាក្យបណ្ដឹងដូចគ្នាបាន[១៦៦]។ បើពាក្យបណ្ដឹងត្រូវបានដកមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ភាគីអាចទាមទារឱ្យតុលាការសងមកវិញនូវចំនួនពាក់កណ្ដាលនៃពន្ធដាក់ពាក្យបណ្ដឹងដែលខ្លួនបានបង់[១៦៧]។ ក្នុងករណី

[១៦២] មាត្រា ២១៧ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦៣] មាត្រា ២១៧ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១ និងកថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦៤] មាត្រា ២១៧ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ និងកថាខណ្ឌទី ៤ វាក្យខណ្ឌទី ១ និងវាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦៥] មាត្រា ២១៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦៦] មាត្រា ២១៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

ដើមចោទ និង ចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម ឬការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីក្នុងអំឡុងពេល ១ ខែត្រូវចាត់ទុកថា បានដកពាក្យបណ្តឹង[១៦៨]។

**កថាខណ្ឌទី ៣ ការបញ្ចប់វិវាទកិច្ចសន្យាដោយស្វ័យប្រវត្តិ**

ការបញ្ចប់បណ្តឹងវិវាទកិច្ចសន្យាដោយស្វ័យប្រវត្តិ ជាការបញ្ចប់បណ្តឹងវិវាទកិច្ចសន្យាដែលកើតឡើងពីភាគីដើមចោទ និង ចុងចម្លើយដោយមានមូលហេតុមួយកំណត់ជាក់លាក់ ដូចជា ភាគីបានទទួលមរណភាព ឬ បានរលត់ដោយការរួមបញ្ចូលនៃនីតិបុគ្គល ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង ឬ សិទ្ធិ ឬ កាតព្វកិច្ចនោះបានធ្លាក់ទៅលើបុគ្គលតែម្នាក់គឺដើមចោទ និង ចុងចម្លើយបានក្លាយជាបុគ្គលតែម្នាក់ ឬ ដោយសារភាគីម្ខាងទៀតគ្មានអ្នកទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀត នោះបណ្តឹងវិវាទកិច្ចសន្យាត្រូវបានបញ្ចប់។ ករណីនេះតុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្តឹងនោះ មានខ្លឹមសារថា បណ្តឹងវិវាទកិច្ចសន្យាត្រូវបានបញ្ចប់ដោយសារមរណភាពនៃភាគី ឬ បណ្តឹងត្រូវបានបញ្ចប់ដោយសារតែសិទ្ធិ និង កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះធ្លាក់ទៅលើបុគ្គលតែម្នាក់[១៦៩]។

[១៦៧] មាត្រា ៦១ កថាខណ្ឌទី ៨ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦៨] មាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

[១៦៩] មាត្រា ១៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## • សេចក្តីសន្និដ្ឋាន

ផ្អែកតាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា ការដោះស្រាយវិវាទកិច្ចសន្យានៅតុលាការសាលាដំបូងក្នុងប្រទេសកម្ពុជា ពិតជាផ្តល់នូវសារៈប្រយោជន៍សំខាន់ខ្លាំងណាស់សម្រាប់គូភាគីវិវាទ និង ប្រជាពលរដ្ឋទូទៅ តាមរយៈការដោះស្រាយដ៏ត្រឹមត្រូវតាមប្រព័ន្ធតុលាការ ដោយផ្អែកលើច្បាប់ធរមាន ដើម្បីការពារនូវសិទ្ធិស្របច្បាប់របស់ភាគី។ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូងនេះ មានលំនាំនៃការដោះស្រាយប្រហាក់ប្រហែលគ្នា និងរឿងវិវាទរដ្ឋប្បវេណីទូទៅដែរ ពីព្រោះនីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យានេះ វាស្ថិតនៅក្រោមរដ្ឋប្បវេណីទូទៅ ហេតុដូច្នេះហើយ ទើបធ្វើឱ្យនីតិវិធីនៃការដោះស្រាយមានភាពដូចគ្នា។

នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង បានបង្ហាញប្រាប់អំពីការដោះស្រាយវិវាទកិច្ចសន្យា ដែលតុលាការធ្លាប់ធ្វើការដោះស្រាយកន្លងមក និង កំពុងធ្វើការដោះស្រាយតាមរយៈសាលក្រមស្ថាពរ និង ច្បាប់ធរមាន ។ នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាជានីតិវិធីដែលកំណត់អំពីរបៀបដោះស្រាយដោយការអនុវត្តសិទ្ធិ ទំនាក់ទំនងគតិយុត្តរបស់ភាគីដែលត្រូវបានទទួលស្គាល់ដោយច្បាប់ធរមាន ហើយមានការបំពានពីភាគីម្ខាងទៀត ហេតុនេះដើម្បីអនុវត្តនូវសិទ្ធិរបស់ខ្លួនបានតាមរយៈប្រព័ន្ធតុលាការត្រូវកំណត់អំពីវិធានក្នុងការអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ខ្លួនដែលត្រូវបានគេបំពាន ឬ ត្រូវការការទទួលស្គាល់អំពីច្បាប់ ដើម្បីអាចអនុវត្តសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះជាដើម ។ យន្តការអនុវត្តនូវសិទ្ធិ ដើម្បីអាចកំណត់ជាស្ថាពរអំពីភាពមាន ឬ មិនមាននៃសិទ្ធិ និង កាតព្វកិច្ចដែលទំនាក់ទំនងជាមួយបុគ្គលឯកជន និង របៀបនៃការសម្រេចសិទ្ធិនោះតាមរយៈការអនុវត្តដោយបង្ខំ ប្រសិនបើគ្មានការអនុវត្តដោយស្ម័គ្រចិត្តរបស់កូនបំណុលនៃការអនុវត្ត ដែលសិទ្ធិទាំងនោះត្រូវបានកំណត់ជាស្ថាពរ ហើយក៏មានវិធានសម្រាប់បង្ការ ឬរាំងកុំឱ្យសិទ្ធិទាំងនោះត្រូវបានខូចខាត ឬពិបាកក្នុងការអនុវត្ត ខណៈពេលដែលកំពុងវិវាទគ្នា ដើម្បីអាចអនុវត្តសិទ្ធិទាំងនោះនាពេលអនាគត។

## • អនុសាសន៍

នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាតុលាការនៅសាលាដំបូង បានបង្ហាញឱ្យឃើញនូវចំណុចល្អ និង ចំណុចខ្វះខាតខ្លះៗ ដែលទាក់ទងទៅនឹងនីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យាតុលាការនៅសាលាដំបូង។ ដើម្បីឱ្យការដោះស្រាយវិវាទកិច្ចសន្យាដោយតុលាការនៅសាលាដំបូង

មានលក្ខណៈកាន់តែល្អប្រសើរជាងនេះថែមទៀតនោះ គឺត្រូវមានដូចជា ការចូលរួមពីគ្រប់ភាគីវាទក្នុងន័យអនុវត្តច្បាប់ ត្រូវមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធក្នុងសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ឱ្យមានសុក្រឹត្យភាព តម្លាភាព យុត្តិធម៌ ។ បង្កើនការអនុវត្តច្បាប់ដែលមាន ជៀសវាងមានអំពើពុករលួយ ឬ បក្សពួកនិយមដែលនាំឱ្យប៉ះពាល់ដល់សាលាជម្រះក្ដី ធ្វើឱ្យបុគ្គលឯកជននានាបាត់បង់លើស្ថាប័នមួយនេះ។

# ឯកសារយោង

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១។

ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១០។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ភ្នំពេញ ២០០៩ ២០១០។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ភ្នំពេញ ២០០៧។

សេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ក្រសួងយុត្តិធម៌ ភ្នំពេញ ២០០៨។

ក្រមរដ្ឋប្បវេណី ភាគ ១ ដល់ភាគ ៦ ភ្នំពេញ បោះពុម្ពនៅក្នុងខែ មីនា ឆ្នាំ ២០១២

ហ៊ីង ធីឫទ្ធិ អត្ថាធិប្បាយច្បាប់ ភាគ ៣ ក្នុងរឿងរដ្ឋប្បវេណី សម្រាប់ប្រជារាស្ត្រសាមញ្ញ ភ្នំពេញ បោះពុម្ពលើកទី ២ ឆ្នាំ ២០០៧ ។

ទម្រង់ឯកសារ កិច្ចការនៅតុលាការ។

អៀវ ប៊ុនរ៉េង បច្ចេកទេសសវនាការនៃមេធាវីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០១១។

ជួន ស៊ុនឡេង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ ២០០១ ២០០២។

សមាគម អាហុជ ផ្លូវនៃបណ្តឹង ភ្នំពេញ ២០០៨។

វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលជាការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៧។

ទីស្តីការគណៈរដ្ឋមន្ត្រីគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧។

សទ្ទានុក្រមនៃពាក្យច្បាប់ (ច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ការទូត) បោះពុម្ពលើកទី ១ ដោយ ISB។

# សេចក្តីផ្តើម

# ជំពូកទី ១
# វិវាទនៃកិច្ចសន្យា

# ជំពូកទី ២
# សមត្ថកិច្ចតុលាការសាលាដំបូងលើវិវាទកិច្ចសន្យា

# ជំពូកទី ៣
# នីតិវិធីនៃការដោះស្រាយវិវាទកិច្ចសន្យា

# ឯកសារយោង

# ឧបសម្ព័ន្ធ១

# ឧបសម្ព័ន្ធ២

# ឧបសម្ព័ន្ធ៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងរដ្ឋប្បវេណី លេខ ២០៧០ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣

-សញ្ញាណរឿងក្តី

-ប្តឹងសុំទាមទារប្រាក់

-សាលក្រមរដ្ឋប្បវេណី លេខ ៥៣ (យ) ត.ព.រ.វ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៤ និងប្រកាសសាលក្រមនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ លើសំណុំរឿងរដ្ឋប្បវេណី លេខ ២០៧០ ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៣

**ចៅក្រមជំនុំជម្រះ**

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

កញ្ញា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទអង្គការប្រឹក្សាហិរញ្ញវត្ថុ មានស្នាក់ការកណ្តាលផ្ទះលេខ ប្លុកB ផ្លូវលេខ ៣១៨ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងដោយលោក ។

មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ ។

និងចុងចម្លើយឈ្មោះ ភេទប្រុស ឆ្នាំកំណើត ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ និងឈ្មោះ ភេទស្រី ឆ្នាំកំណើត ០២ ខែ ឧសភា ឆ្នាំ ១៩៨២ មានទីលំនៅ បច្ចុប្បន្នផ្ទះលេខ ៩០ អា ផ្លូវលំ ភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

I/អង្គហេតុ និងចំណុចវិវាទ

ក-<u>ការទាមទាររបស់ដើមចោទ</u>

១. សងប្រាក់ដើមចំនួន ៤៧២២$ (បួនពាន់ប្រាំពីររយម្ភៃពីរដុល្លារអាមេរិក) ។

២. បង់ការប្រាក់ពិន័យចំនួន ២% (ពីរភាគរយ) ក្នុង ១ខែ ចាប់ពីថ្ងៃខកខានមិនបានបង់ ។

៣. បង់ប្រាក់យឺតយ៉ាវ គិតចាប់តាំងពីថ្ងៃខកខានមិនបានបង់តាមតារាងបង់ប្រាក់រំលោះ ។

៤.ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ចំនួន ៤០០០$ (បួនពាន់ដុល្លារអាមេរិក) ។

៥.ក្នុងករណីឈ្មោះ និង ពុំមានប្រាក់សងតាមចំនួនខាងលើទេសុំរឹបអូសអចលនទ្រព្យដាក់បញ្ចាំ លក់ឡាយឡុង ដើម្បីសងបំណុលមក អង្គការប្រឹក្សាហិរញ្ញវត្ថុ របស់ខ្ញុំបាទវិញ ។

ខ-<u>ការអះអាងរបស់សាមីភាគី</u>

-មេធាវីតំណាងឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ កាលពីថ្ងៃទៅ ២២ ខែមេសា ឆ្នាំ២០១៣ ឈ្មោះ និង បាន

មកអង្គការប្រឹក្សាហិរញ្ញវត្ថុរបស់កូនក្តីខ្ញុំដើម្បីខ្ចីការប្រាក់ចំនួន ៥០០០$ ដោយយកដីស្រែចំនួន ២ប្លង់ ធ្វើជាទ្រព្យដាក់ធានាសំណង និងទូទាត់បង់ប្រាក់ប្រចាំខែជាលក្ខណៈបង់រំលោះទាំងការ ទាំងដើម តាមតារាងកាលវិភាគសងប្រាក់ឲ្យបានទៀងទាត់ ។ ក៏ប៉ុន្តែ ក្រោយពីខ្ចីប្រាក់កូនក្តីខ្ញុំរួចមក ឈ្មោះ និងឈ្មោះ អនុវត្តតាមតារាងកាលវិភាគសងប្រាក់បានចំនួនតែ ២ខែ ប៉ុណ្ណោះ គឺនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៣ ហើយក្រោយមកភាគីទាំង ២ មិនព្រមចូលមក បង់ប្រាក់តាមតារាងកាលវិភាគសងប្រាក់របស់អង្គការទេ ទោះបីខាងអង្គការធ្វើការ ទំនាក់ទំនង ទៅ ឈ្មោះ និងឈ្មោះ ជាច្រើនលើកច្រើនសារ ក៏ឈ្មោះទាំងពីរនាក់ខាង លើ មិនព្រមចូលមកបង់ប្រាក់តាមកាលវិភាគសងប្រាក់ដដែល ដែលទង្វើរបស់ឈ្មោះ និង ឈ្មោះ បានស្តែងចេញនូវអំពើទុច្ចរិតមកលើកូនក្តីខ្លួន ។ ខ្ញុំបានសុំ សំណូមពរឲ្យ តុលាការចេញសាលក្រមៈ

១.ឲ្យឈ្មោះ និងឈ្មោះ សងប្រាក់ដើមចំនួន ៤៧២២$ ។

២.ឲ្យឈ្មោះ និងឈ្មោះ បង់ប្រាក់ការពិន័យចំនួន ២% ក្នុង ១ខែ ចាប់ពីថ្ងៃខកខានមិនបានបង់

៣.ឲ្យឈ្មោះ និងឈ្មោះ បង់ប្រាក់យឺតយ៉ាវគិតចាប់ពីថ្ងៃខកខានមិន បានបង់តាមតារាងបង់ប្រាក់រំលោះ

៤.ការខាតបង់ពេលវេលា និងសេវាច្បាប់ចំនួន ៨០០០$

៥.ក្នុងករណីឈ្មោះ និងឈ្មោះ ពុំមានសងប្រាក់ទេ សុំរឹបអូស អចលនទ្រព្យដាក់បញ្ចាំលក់ឡាយឡុង ដើម្បីសងបំណុល ។

-ចុងចម្លើយអវត្តមានដោយគ្មានមូលហេតុ

-មេធាវីតំណាងឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍នៅនីតិវិធីទាញហេតុផលផ្ទាល់មាត់ថា ៖ ខ្ញុំបាទនៅតែរក្សាសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៤ ទុកជាបានការដដែល ។ ខ្ញុំបាទសំណូមពរឲ្យតុលាការចេញសាលក្រមៈ

១.សងប្រាក់ដើមចំនួន ៤៧២២$ ។

២.បង់ប្រាក់ការពិន័យចំនួន ២% ក្នុង ១ខែ ចាប់ពីថ្ងៃខកខានមិនបានបង់

៣.បង់ប្រាក់យឺតយ៉ាវគិតចាប់ពីថ្ងៃខកខានមិន បានបង់តាមតារាងបង់ប្រាក់រំលោះ

៤.ការខាតបង់ពេលវេលា និងសេវាច្បាប់ចំនួន ៨០០០$

៥.ក្នុងករណីឈ្មោះ និងឈ្មោះ ពុំមានសងប្រាក់ទេ សុំរឹបអូស អចលនទ្រព្យដាក់បញ្ចាំលក់ឡាយឡុង ដើម្បីសងបំណុលមកកូនក្តីខ្ញុំបាទ ។

-ចុងចម្លើយអវត្តមានដោយគ្មានមូលហេតុ

**II/ចំណុចវិវាទៈ**

តើត្រូវទទួលស្គាល់ការទាមទាររបស់មេធាវីតំណាងឲ្យដើមចោទដែរ ឬទេ?

# សំអាងហេតុ

១.តាមកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ និងកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ បានឲ្យដឹងថា ចុងចម្លើយឈ្មោះ និងឈ្មោះ ខ្ចីចងការប្រាក់ចំនួន ៥០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ពីអង្គការប្រឹក្សាហិរញ្ញវត្ថុ តំណាងដោយដើមចោទឈ្មោះ ពិតប្រាកដមែន ។

២.ចុងចម្លើយបានធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ និងកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ ជាមួយដើមចោទ ដោយសន្យាសងក្នុងរយៈពេល ៣៦ខែ និងមានការប្រាក់ ២% ក្នុង ១ខែ ដោយបង់រំលោះទាំងដើម និងការប្រាក់ ប៉ុន្តែតាមការអះអាងរបស់ដើមចោទ គឺចុងចម្លើយក្រោយពីបានខ្ចីលុយរួចបានបង់ការប្រាក់ និងរំលោះប្រាក់ដើមបានតែរយៈពេល ០២ខែ ប៉ុណ្ណោះក្រោយមកមិនបានបង់រហូត ។ ដូចនេះ ចុងចម្លើយមិនបានអនុវត្ត និងគោរពកាតព្វកិច្ចរបស់ខ្លួនឡើយ ។ ដូច្នេះ ចំពោះការទាមទាររបស់ដើមចោទឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ៤៧២២$ (បួនពាន់ប្រាំពីររយម្ភៃពីរដុល្លារអាមេរិក) មានមូលហេតុត្រឹមត្រូវដោយហេតុថា ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ។ ក៏ប៉ុន្តែតាមកិច្ចសន្យាខាងលើ ឃើញការប្រាក់ ដែលបានកំណត់ក្នុងកិច្ចសន្យានេះមានចំនួន ២% ក្នុង ០១ខែ ដែលលើសពីចំនួនច្បាប់ដែលបានកំណត់ ។ ដូចនេះ គប្បីតុលាការពិចារណាលើការប្រាក់តាមច្បាប់កម្រិត ។

៣.ចំពោះការទាមទាររបស់ដើមចោទបានទាមទារឲ្យចុងចម្លើយ បង់ប្រាក់ពិន័យចំពោះការយឺតយ៉ាវ គិតចាប់តាំងពីថ្ងៃខកខានមិនបានបង់តាមតារាងបង់ប្រាក់រំលោះ មានមូលហេតុត្រឹមត្រូវដោយសារចុងចម្លើយយឺតយ៉ាវក្នុងការបង់ប្រាក់ និងរំលោះប្រាក់ដើម និងដោយយោងតាមប្រការ ២ និងប្រការ ៦ នៃកិច្ចសន្យាស្តីពីការប្រាក់ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ ។

៤.ចំពោះការទាមទាររបស់ដើមចោទបានទាមទារសំណងជម្ងឺចិត្ត នៃការខាតបង់ពេលវេលាចំនួន ៤០០០$ (បួនពាន់ដុល្លារអាមេរិក) ដោយសារចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យាខ្ចីចងការប្រាក់ខាងលើនេះ មិនអាចលើកយកមកពិចារណាបានទៀតទេ ដោយហេតុថាតុលាការបានទទួលស្គាល់ការទាមទារលើប្រាក់ពិន័យ គិតចាប់ពីថ្ងៃខកខានមិនបានបង់តាមតារាងបង់ប្រាក់រំលោះ រួចហើយមានលក្ខណៈសមស្របចំពោះសំណង នៃការខូចខាតដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយរួចហើយ ។ ដូច្នេះ គប្បីតុលាការច្រានចោលការទាមទារនេះ ។

៥.ចំពោះការទាមទាររបស់ដើមចោទក្នុងការឲ្យចុងចម្លើយ សុំឲ្យតុលាការរឹបអូសអចលនវត្ថុរបស់ចុងចម្លើយដាក់បញ្ចាំ លក់ឡាយឡុង ដើម្បីសងបំណុលមកឲ្យដើមចោទ អង្គការប្រឹក្សាហិរញ្ញវត្ថុ គប្បីតុលាការមិនលើកមកពិចារណានោះទេ ដោយទុកសិទ្ធិឲ្យដើមចោទអនុវត្តតាមនីតិវិធីអនុវត្តដោយបង្ខំ ។

៦.ប្រាក់ប្រដាប់ក្តី គប្បីសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ សងប្រាក់៖

ក) ប្រាក់ដើមចំនួន ៤៧២២$ (បួនពាន់ប្រាំពីររយម្ភៃពីរដុល្លារអាមេរិក) ។

ខ) ការប្រាក់ពិន័យចំនួន ១៨% ក្នុង ១ឆ្នាំនៃប្រាក់ដើម ចាប់ពីថ្ងៃខកខានមិនបានបង់ ។

គ) ប្រាក់ឃើតយ៉ាវគិតចាប់តាំងពីថ្ងៃខកខានមិនបានបង់តាមតារាងបង់ប្រាក់រំលោះ ។

ទៅឲ្យដើមចោទអង្គការប្រឹក្សាហិរញ្ញវត្ថុ ។

២-ការទាមទាររបស់ដើមចោទក្រៅពីនេះច្រានចោល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**ចៅក្រម**